បោះពុម្ពនៅរោងពុម្ព ទីស្ដីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ១.៥០០ ច្បាប់



តម្លៃ ២៧៥០ រៀល


ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *


ឆ្នាំទី ៧ លេខ ៤៣ ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩


# រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសម្រេច
- សារាចរ


ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រី រៀងរាល់សប្ដាហ៍

# មាតិកា

## I. ខុទ្ទកាល័យព្រះមហាក្សត្រ

### ១. ព្រះរាជក្រម


១៨-១១-១៩៩៩ -ព្រះរាជក្រម នស/រកម/១១៩៩/១២ ច្បាប់ស្តីពីវិសោធនកម្មមាត្រា ១០. ១១. ១៤. ១៦.១៧.២១.២២. ២៥. ២៦. ២៨. ២៩. ៣០. ៣១. ៣២. ៣៣. ៣៤. ៣៥. ៣៦. ៣៧. ៣៨. ៤០. ៤២. ៤៤ ក្នុងជំពូកទី២ មាត្រា ៥៤. ៥៧. ៥៨ ក្នុងជំពូកទី៤ និងមាត្រា ៥៩. ៦០ ក្នុងជំពូកទី៥ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ១៩៤៤

១៨-១១-១៩៩៩ -ព្រះរាជក្រម នស/រកម/១១៩៩/១៣ ច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ១៩៥៣


### ២-ព្រះរាជក្រឹត្យ


១៦-១១-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/១១៩៩/១៩៧ តែងតាំងឯកឧត្តម សរិទ្ធ សារុន ជាទីប្រឹក្សាសម្តេច ហេង សំរិន អនុប្រធានទី១ រដ្ឋសភា ១៩៧៧

២១-១១-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/១១៩៩/១៩៨ តែងតាំងឥស្សរជនថ្នាក់ដឹកនាំ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មការអចិន្ត្រៃយ៍រៀបចំបេសកកម្មជាតិ អន្តរជាតិ ចំនួនពីររូប ១៩៧៨

២១-១១-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/១១៩៩/១៩៩ បន្ធូរបន្ថយទោសរយៈពេល ០៦ខែ ឲ្យទណ្ឌិតឈ្មោះ ហ៊ាន ម៉ៅខ្លឹង ១៩៧៩


## II. រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


១៦-១១-១៩៩៩ -អនុក្រឹត្យលេខ ៩៩ អនក្រ.បក ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតធនាគារអភិវឌ្ឍន៍ជនបទ ១៩៨០

១៦-១១-១៩៩៩ -អនុក្រឹត្យលេខ ១០០ អនក្រ.បក ស្តីពីការផ្ទេរឥណទាន ១៩៨២

១៧-១១-១៩៩៩ -អនុក្រឹត្យលេខ ១០១ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មការអចិន្ត្រៃយ៍រៀបចំបេសកកម្មជាតិ អន្តរជាតិ ១៩៨៤

១៧-១១-១៩៩៩ -អនុក្រឹត្យលេខ ១០២ អនក្រ.បក ស្ដីពីការផ្ទេរឥណទាន ១៩៩០
១៩-១១-១៩៩៩ -អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្ដីពីការផ្ទេរឥណទាន ១៩៩២
១៩-១១-១៩៩៩ -អនុក្រឹត្យលេខ ១០៤ អនក្រ.បក ស្ដីពីការផ្ទេរឥណទាន ១៩៩៣
២៦-១១-១៩៩៩ -អនុក្រឹត្យលេខ ៥៣៧ អនក្រ.តត ស្ដីពីការតែងតាំងក្រុមប្រឹក្សាភិបាល
នៃមន្ទីរពេទ្យកាល់ម៉ែត ១៩៩៤
១៨-១១-១៩៩៩ -អនុក្រឹត្យលេខ ៥៣៨ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ១៩៩៥
១៩-១១-១៩៩៩ -អនុក្រឹត្យលេខ ៥៣៩ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ១៩៩៦

## ២-សេចក្ដីសម្រេច

១៦-១១-១៩៩៩ -សេចក្ដីសម្រេចលេខ ៧៥ សសរ. ស្ដីពីការបង្កើតសមាសភាព នៃគណៈ
កម្មការជាតិអូឡាំពិកកម្ពុជា ១៩៩៧
១៦-១១-១៩៩៩ -សេចក្ដីសម្រេចលេខ ៧៦ សសរ. ស្ដីពីការផ្លាស់ប្ដូរសមាសភាព នៃគណៈ
កម្មការជាតិអូឡាំពិកកម្ពុជា ១៩៩៨

# III. ឯកសារបណ្ដាក្រសួង

## ១-ទីស្ដីការគណៈរដ្ឋមន្ត្រី

### ១. ប្រកាស

១៧-១១-១៩៩៩ -ប្រកាសលេខ ១៥២ ប្រក. ស្ដីពីការតែងតាំងមន្ត្រីរាជការ ១៩៩៩

### ២. សេចក្ដីជូនដំណឹង

១៦-១១-១៩៩៩ -សេចក្ដីជូនដំណឹងលេខ ១៦៥៨ សជណ. ស្ដីពីអក្ខរៈត្រឹមត្រូវ នៃ
ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៩/១៩៧ ២០០០

## ២-ធនាគារជាតិនៃកម្ពុជា

### ប្រកាស

១៦-១១-១៩៩៩ -ប្រកាសលេខ ធ២.៩៩.១២១ ប្រក. ស្ដីពីប្រព័ន្ធគណនេយ្យរបស់ធនាគារ
ជាតិ នៃកម្ពុជា ២០០១

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ១- ព្រះរាជក្រម

### ព្រះរាជក្រម នស/រកម/១១៩៩/១២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់ទតរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ទតព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើជាផ្លូវការនូវច្បាប់ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៥០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ទតព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ទតព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់ទតព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់ទតព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី និងអំពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៦ មាត្រា១៧ មាត្រា២១ មាត្រា២២ មាត្រា២៥ មាត្រា២៦ មាត្រា២៨ មាត្រា២៩ មាត្រា៣០ មាត្រា៣១ មាត្រា៣២ មាត្រា៣៣

មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៤០ មាត្រា៤២ មាត្រា៤៤ ក្នុងជំពូកទី២ មាត្រា៥៤ មាត្រា៥៧ មាត្រា៥៨ ក្នុងជំពូកទី៤ និង មាត្រា៥៩ មាត្រា៦០ ក្នុងជំពូកទី៥ នៃច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី២ និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមទំរង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គលើកទី២ នីតិកាលទី១ ដែលមានសេចក្ដីទាំងស្រុងដូចតទៅ ៖

**ច្បាប់**

**ស្ដីពី**

**វិសោធនកម្មមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៦ មាត្រា១៧ មាត្រា២១ មាត្រា២២ មាត្រា២៥ មាត្រា២៦ មាត្រា២៨ មាត្រា២៩ មាត្រា៣០ មាត្រា៣១ មាត្រា៣២ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៤០ មាត្រា៤២ មាត្រា៤៤ ក្នុងជំពូកទី២ មាត្រា៥៤ មាត្រា៥៧ មាត្រា៥៨ ក្នុងជំពូកទី៤ និង មាត្រា៥៩ មាត្រា៦០ ក្នុងជំពូកទី៥ នៃច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម**

**មាត្រាតែមួយ.-** មាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៦ មាត្រា១៧ មាត្រា២១ មាត្រា២២ មាត្រា២៥ មាត្រា២៦ មាត្រា២៨ មាត្រា២៩ មាត្រា៣០ មាត្រា៣១ មាត្រា៣២ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៤០ មាត្រា៤២ មាត្រា៤៤ ក្នុងជំពូកទី២ មាត្រា៥៤ មាត្រា៥៧ មាត្រា៥៨ ក្នុងជំពូកទី៤ និងមាត្រា៥៩ មាត្រា៦០ ក្នុងជំពូកទី៥ នៃច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រម នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ត្រូវកែប្រែដូចតទៅ ៖

**មាត្រា១០ថ្មី.-** ការគ្រប់គ្រងនិងកាន់កាប់នូវបញ្ជីកត់ចុះអត្តលេខនៃពាណិជ្ជករ និងក្រុមហ៊ុនពាណិជ្ជកម្ម ដែលហៅថា «បញ្ជីពាណិជ្ជកម្ម» ជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម ។

**មាត្រា១១ថ្មី.-** ក្រសួងពាណិជ្ជកម្មត្រូវបញ្ជូនច្បាប់ចំលងនៃសៀវភៅបញ្ជីពាណិជ្ជកម្ម និងភស្តុតាងឯកសារ ដែលពាក់ព័ន្ធនឹងការចុះបញ្ជីពាណិជ្ជកម្មនីមួយៗរាល់ឆ្នាំ ជូនទៅតុលាការពាណិជ្ជកម្ម ដើម្បីតំកល់ជាឯកសារសំរាប់យុត្តាធិការពាណិជ្ជកម្ម ។

**មាត្រា១៤ថ្មី.-** យ៉ាងយឺតបំផុតដប់ប្រាំថ្ងៃ (១៥ថ្ងៃ) មុនពេលចាប់ផ្ដើមបើកធ្វើពាណិជ្ជកម្មរបស់ខ្លួន ពាណិជ្ជករត្រូវចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនៅកន្លែងដែលខ្លួនធ្វើអាជីវកម្ម ។

ទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មមាននៅតាមមន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង ឬនៅទីកន្លែងផ្សេងទៀត តាមការកំណត់របស់ក្រសួងពាណិជ្ជកម្ម ។

ពាណិជ្ជករត្រូវប្រគល់ទៅទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្ម នូវប្រតិវេទន៍មួយធ្វើជាពីរច្បាប់ មានចុះហត្ថលេខា ឬស្នាមមេដៃរបស់សាមីខ្លួន ។

ប្រតិវេទន៍នេះត្រូវសរសេរលើលិខិតគំរូមួយ ដែលមន្ត្រីចុះបញ្ជីពាណិជ្ជកម្មបានផ្តល់ឲ្យ ។ ប្រតិវេទន៍ត្រូវចែងអំពី :

១- នាមត្រកូល និងនាមខ្លួនរបស់ពាណិជ្ជករ និងលេខ នៃលិខិតអត្តសញ្ញាណរបស់ខ្លួន ។

២- នាមប្រើប្រាស់ក្នុងពាណិជ្ជកម្ម ឬរហស្សនាម ។

៣- ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត ព្រមទាំងអាសយដ្ឋានផ្ទាល់ខ្លួន ។

៤- សញ្ជាតិដើម ហើយក្នុងករណីដែលសាមីខ្លួនបានទទួលសញ្ជាតិមួយផ្សេងទៀត ត្រូវបញ្ជាក់អំពីរបៀប និងថ្ងៃ ខែ ឆ្នាំ ដែលបានទទួលសញ្ជាតិនេះ ។

៥- កម្មវត្ថុពាណិជ្ជកម្ម ។

៦- ទីកន្លែងធ្វើអាជីវកម្ម និងអាសយដ្ឋានគ្រឹះស្ថាន ឬសាខានៃមូលនិធិពាណិជ្ជកម្មដែលមានទីតាំងនៅព្រះរាជាណាចក្រកម្ពុជា

៧- ផ្លាកសញ្ញាពាណិជ្ជកម្មនៃគ្រឹះស្ថាន និងហត្ថលេខាផ្ទាល់របស់សាមីខ្លួន ព្រមទាំងស្នាមត្រាគំរូ ។

៨- លិខិតអត្តសញ្ញាណរបស់អ្នកតំណាងពេញសិទ្ធិ ដែលទទួលភារៈក្នុងការសុំចុះ បញ្ជីពាណិជ្ជករ ។

៩- គ្រឹះស្ថានពាណិជ្ជកម្មដែលអ្នកស្នើសុំបានធ្វើអាជីវកម្មពីមុន ឬគ្រឹះស្ថានពាណិជ្ជកម្មដែលអ្នកស្នើសុំកំពុងធ្វើអាជីវកម្មនៅក្នុងរង្វង់សមត្ថកិច្ច ក្រសួងពាណិជ្ជកម្ម ។

១០- សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់អ្នកស្នើសុំថា គ្មានជាប់ចោទណាមួយក្នុងកិច្ចការពាណិជ្ជកម្ម ។

១១- ក្នុងករណីចាំបាច់ លិខិតអនុញ្ញាតឲ្យប្រកបមុខរបរ ចំពោះមុខរបរណា ឬចំពោះកម្មវត្ថុពាណិជ្ជកម្មណាដែលត្រូវឲ្យមានសេចក្តីអនុញ្ញាត ។ មន្ត្រីចុះបញ្ជីពាណិជ្ជកម្មត្រូវចម្លងសេចក្តីក្នុងប្រតិវេទន៍ចូលក្នុងបញ្ជីពាណិជ្ជកម្ម ដោយប្រគល់ប្រតិវេទន៍នេះ មួយច្បាប់ក្នុងចំណោមប្រតិវេទន៍ទាំងពីរច្បាប់ ជូនដល់អ្នកស្នើសុំចុះឈ្មោះដោយបញ្ជាក់នៅខាងក្រោមថា "បានចម្លងចូលបញ្ជីរួចហើយ" ។

មាត្រា១៦ថ្មី .- ការចុះនិទ្ទេសផ្សេងៗដែលមានចែងក្នុងមាត្រា១៥ នៃច្បាប់នេះ ជាភារកិច្ចផ្ទាល់ខ្លួនរបស់ពាណិជ្ជករ ។ ប៉ុន្តែចំពោះករណីដែលមានចែងនៅក្នុងចំណុច ២, ៤និង ៦

នៃមាត្រា១៥ មន្ត្រីចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្មអាចចុះសេចក្តីនោះជាបញ្ញត្តិក្នុងបញ្ជីពាណិជ្ជកម្ម ដែលសាមីពាណិជ្ជករបានចុះឈ្មោះ ។

**មាត្រា១៧ថ្មី .-** គ្រប់ក្រុមហ៊ុន ដែលមានសកម្មភាពពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា ត្រូវចុះក្នុងបញ្ជីពាណិជ្ជកម្ម ទោះបីរបៀបរបបនៃការបង្កើតនិងគ្រប់គ្រងរបស់ក្រុមហ៊ុនទាំងនោះមានលក្ខណៈបែបណាក៏ដោយ ។

ការចុះឈ្មោះនេះ ត្រូវធ្វើឡើងដោយបណ្ណាធិការ ឬអភិបាលនៃសាមី ក្រុមហ៊ុន នៅក្នុងខែនៃការបង្កើតក្រុមហ៊ុន និងដប់ប្រាំថ្ងៃ (១៥ថ្ងៃ) មុនកាលបរិច្ឆេទបើកប្រតិបត្តិការពាណិជ្ជកម្ម ។

អ្នកស្នើសុំចុះឈ្មោះ ត្រូវផ្តល់ជូនទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មនូវប្រតិវេទន៍ចំនួនពីរច្បាប់ មានចុះហត្ថលេខារបស់សាមីខ្លួនអ្នកស្នើសុំព្រមទាំងតំកល់លក្ខន្តិកៈក្រុមហ៊ុនផង ។

ប្រតិវេទន៍ ដែលមន្ត្រីចុះបញ្ជីពាណិជ្ជកម្មផ្តល់ជូននោះត្រូវចែងអំពី :

១- នាមត្រកូលនិងនាមខ្លួន រហស្សនាមរបស់សមាជិកក្រុមហ៊ុន ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត ស្ថានភាពគ្រួសារ និងសញ្ជាតិ ។

២- ស្លាកសញ្ញារបស់ក្រុមហ៊ុន ។

៣- កម្មវត្ថុនៃក្រុមហ៊ុន ។

៤- ទីកន្លែងទាំងឡាយដែលក្រុមហ៊ុនមានគ្រឹះស្ថានហើយមានសាខា ឬទីភ្នាក់ងារ នៅព្រះរាជាណាចក្រកម្ពុជា ។

៥- នាមនៃសមាជិកឬតតិយជនដែលមានការអនុញ្ញាតឲ្យគ្រប់គ្រង ចាត់ចែង ចុះចាត់ចែង និងចុះហត្ថលេខាជំនួសមុខក្រុមហ៊ុន ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើតនៃអ្នកទាំងនេះ ។

៦- ដើមទុនរបស់ក្រុមហ៊ុន ប្រភពដើមទុន និងចំនួនទឹកប្រាក់ ឬវត្ថុមានតំលៃដែលផ្តល់ដោយសមាជិកភាគហ៊ុន ប្រសិនបើជាក្រុមហ៊ុនដោយភាគហ៊ុន ។

៧- ថ្ងៃ ខែ ឆ្នាំ ដែលក្រុមហ៊ុននោះចាប់ផ្តើម និងបញ្ចប់ ។

៨- ទ្រង់ទ្រាយក្រុមហ៊ុន ។

៩- ហត្ថលេខាគំរូរបស់សមាជិក ឬតតិយជនដូចមានចែងនៅចំណុចលេខ៥ នៃមាត្រានេះ និងស្នាមត្រាគំរូរបស់ក្រុមហ៊ុន ។

១០- លិខិតបញ្ជាក់អំពីការតំកល់លើកមុនចេញដោយបរទេស ។

១១- សេចក្តីប្រកាសដោយសុច្ចរិតរបស់អ្នកស្នើសុំថា គ្មានជាប់ទោសណាមួយក្នុងកិច្ចការពាណិជ្ជកម្ម វត្ថុប្រើប្រាស់ពិរុទ្ធប្រឆាំងមនុស្ស ។

មាត្រា២១ថ្មី .- ប្រតិវេទន៍ធ្វើឡើងជាពីរច្បាប់ត្រូវបានគេដាក់ដោយអ្នកស្នើសុំ ឬដោយអាណត្តិគាហក របស់សាមីជននោះ ក្នុងករណីនេះ អាណត្តិគាហកត្រូវមានលិខិតប្រគល់សិទ្ធិ អំណាច ដែលត្រូវតំកល់ទុកនៅទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

មាត្រា២២ថ្មី .- បើប្រតិវេទន៍ត្រូវបានគេដាក់ផ្ទាល់ដោយអ្នកស្នើសុំនោះ មន្ត្រីចុះបញ្ជីពាណិជ្ជកម្មត្រូវពិនិត្យពិច័យអត្តសញ្ញាណរបស់សាមីខ្លួនឲ្យបានច្បាស់លាស់ ។ បើសិនប្រតិវេទន៍នេះ ត្រូវបានគេនាំទៅតំកល់ទុកដោយអាណត្តិគាហក មន្ត្រីចុះបញ្ជីពាណិជ្ជកម្មត្រូវតំរូវឲ្យមានការបញ្ជាក់អំពីអត្តសញ្ញាណរបស់អាណត្តិគាហក ឬការបញ្ជាក់អំពីស្នាមមេដៃ . បើអាណត្តិគាហកមិនចេះចុះហត្ថលេខា និងតំរូវឲ្យបង្ហាញលិខិតបញ្ជាក់អត្តសញ្ញាណ របស់អ្នកស្នើសុំ ។

មាត្រា២៥ថ្មី .- មន្ត្រីចុះបញ្ជីពាណិជ្ជកម្មនឹងផ្ទៀងផ្ទាត់មើលក្រោមការទទួលខុសត្រូវផ្ទាល់ របស់ខ្លួន អំពីគ្រប់ឯកសារទាំងឡាយដែលបានបញ្ញត្តិ ។ មន្ត្រីចុះបញ្ជីពាណិជ្ជកម្មត្រូវចុះនៅលើផ្នែកខាងលើនៃប្រតិវេទន៍នូវ :

១- ថ្ងៃ ខែ ឆ្នាំ ម៉ោងនៃការតំកល់ទុក និងទីកន្លែងក្រសួងពាណិជ្ជកម្ម ។

២- លេខរៀងរបស់ប្រតិវេទន៍តាមលំដាប់លេខជាបន្តបន្ទាប់ ក៏ប៉ុន្តែការចុះលេខនេះ ត្រូវចាប់ផ្តើមឡើងវិញចាប់ពីថ្ងៃទី ០១ មករា ជារៀងរាល់ឆ្នាំ ។

៣- អត្តលេខសំគាល់នៅតាមសៀវភៅនៃសកម្មភាពរបស់ពាណិជ្ជករ ដែលចុះក្នុងបញ្ជីវិភាគដែលនឹងមានចែងខាងក្រោម ។

ចំពោះអ្នកធ្វើប្រតិវេទន៍ណាដែលមិនបានផ្តល់នូវឯកសារគ្រប់គ្រាន់ ដល់ការចុះបញ្ជី នឹងត្រូវបានអនុញ្ញាតរយៈពេលពិសេសចំនួនដប់ប្រាំថ្ងៃ (១៥ថ្ងៃ)បន្ថែម ។

មាត្រា២៦ថ្មី .- ដោយបានឃើញប្រតិវេទន៍ជាលក្ខណៈត្រឹមត្រូវ និងរាល់ឯកសារតំកល់ តំកល់ទុក មន្ត្រីចុះបញ្ជីពាណិជ្ជកម្មនឹងផ្តល់នូវវិញ្ញាបនប័ត្រចុះបញ្ជីហៅថា "សំរង់" ដែលមានចែងអត្តលេខសំគាល់ចុះក្នុងបញ្ជីពាណិជ្ជកម្ម ។ វិញ្ញាបនប័ត្រនេះ ស្ថិតក្នុងលក្ខណៈបណ្តោះអាសន្នក្នុងពេលរយៈមួយខែ (១ខែ) គិតចាប់ពីកាលបរិច្ឆេទ ដែលបានផ្តល់ជូន ។ ក្នុងពេលវេលានេះ ប្រសិនបើរកឃើញថាជាប្រតិវេទន៍ក្លែងបន្លំ មន្ត្រីចុះបញ្ជី

ពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម អាចជំទាស់នឹងការចុះបញ្ជីនិងលុបចោលអត្តសញ្ញាណសំគាល់ ដែលមានចុះក្នុងបញ្ជីហើយនោះ ។

មន្ត្រីចុះបញ្ជីពាណិជ្ជកម្មដែលផ្ដល់នូវវិញ្ញាបនប័ត្រក្លែងបន្លំ ដែលបានធ្វើឡើងដោយដឹងហេតុផលសព្វគ្រប់ ត្រូវទទួលទោសតាមច្បាប់ ។

**មាត្រា២៨ថ្មី .-** កាលណាបើពាណិជ្ជករណាម្នាក់ឈប់ប្រកបពាណិជ្ជកម្មរបស់ខ្លួន ឬទទួល មរណភាព ដោយពុំបានធ្វើអនុប្បទាននូវមូលនិធិពាណិជ្ជកម្មរបស់ខ្លួន ឬកាលណាបើក្រុមហ៊ុនណាមួយត្រូវរំលាយនោះ ត្រូវលុបឈ្មោះពាណិជ្ជករនោះ ឬក្រុមហ៊ុននោះចេញពីបញ្ជី។

បើសិនជាគ្មានការសុំលុបឈ្មោះដោយពាណិជ្ជករឬដោយអ្នកទទួលមរតក ឬដោយអ្នកជំរះបញ្ជី ការលុបឈ្មោះចេញពីបញ្ជីនេះត្រូវធ្វើឡើងដោយបញ្ញត្តិតាមសេចក្ដីសំរេចរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

រាល់ឯកសារដែលពាក់ព័ន្ធនឹងការលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្មនេះ ត្រូវចំលងជូនទៅតុលាការពាណិជ្ជកម្ម ដើម្បីតំកល់ជាឯកសារសំរាប់លេខាធិការពាណិជ្ជកម្ម។

**មាត្រា២៩ថ្មី .-** ជនណាក៏ដោយអាចសុំឲ្យមន្ត្រីចុះបញ្ជីពាណិជ្ជកម្មចេញឲ្យខ្លួននូវវិញ្ញាបនប័ត្រ បញ្ជាក់អំពីព័ត៌មានទាំងឡាយ ដែលមានចុះក្នុងបញ្ជីពាណិជ្ជកម្ម ។ បើគ្មានចុះបញ្ជីទេ មន្ត្រីចុះបញ្ជីពាណិជ្ជកម្ម ត្រូវចេញវិញ្ញាបនប័ត្របញ្ជាក់ថា គ្មានចុះបញ្ជី ។

ការធ្វេសប្រហែស ឬការមិនព្រមចេញវិញ្ញាបនប័ត្រក្នុងរយៈពេលមួយសប្ដាហ៍គិតចាប់ពីថ្ងៃស្នើសុំ នឹងបណ្ដាលឲ្យមានទណ្ឌកម្មតាមវិន័យចំពោះមន្ត្រីចុះបញ្ជីពាណិជ្ជកម្មព្រមទាំងមានការសងជំងឺចិត្តផង ។

សេចក្ដីចំលង ដែលមន្ត្រីចុះបញ្ជីពាណិជ្ជកម្មចេញឲ្យនោះ មិនត្រូវចែងសាលក្រមប្រកាសធនក្ស័យឬការជំរះបញ្ជីតាមផ្លូវតុលាការទេ បើក្រោយមកមាននីតិសម្បទាឡើងវិញ ។ សេចក្ដីចំលងក៏មិនត្រូវចុះផងដែរនូវសាលក្រម ឬសាលដីកាហាមឃាត់មិនឲ្យធ្វើពាណិជ្ជកម្ម ឬសាលក្រម សាលដីកាតែងតាំងក្រុមប្រឹក្សាជំនួយ បើមានលើកការហាមឃាត់ចេញរួចហើយ ។

**មាត្រា៣០ថ្មី .-** បញ្ជីពាណិជ្ជកម្ម ដែលតំកល់ទុកនៅទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម មានពីរបែប គឺ :

១- បញ្ជីកាលប្បវត្តិ

២- បញ្ជីវិភាគ

មាត្រា៣១ថ្មី .- ប្រតិវេទន៍ត្រូវចុះក្នុងបញ្ជីកាលប្បវត្តិ តាមលំដាប់នៃការតំកល់ទុកនៅទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្ម និងតាមលេខដែលចុះ ។

ត្រូវប្រគល់ក្នុងសន្លឹកនៃប្រតិវេទន៍មួយសន្លឹក ដែលដាច់ចេញពីគល់បញ្ជីហៅថា "សំអប់" ជាសំគាល់នៃការតំកល់ទុកដោយមានចែងនិទ្ទេសដូចតទៅ :

១- លេខរៀងនៃប្រតិវេទន៍

២- ថ្ងៃ ខែ ឆ្នាំ ម៉ោងនៃការតំកល់ទុក និងទីកន្លែងនៃក្រសួងពាណិជ្ជកម្ម

៣- នាមត្រកូល នាមខ្លួន ផ្លាកសញ្ញាក្រុមហ៊ុន និងលំនៅដ្ឋានអ្នកធ្វើប្រតិវេទន៍ ។

ចំណែកឯបញ្ជីវិភាគវិញ មានទ្រង់ទ្រាយជាតារាងដែលត្រូវចុះជាអាទិ៍នូវលេខថ្ងៃ ខែ ឆ្នាំ ម៉ោងនៃការតំកល់ទុក អត្តលេខ នាមករណ៍ក្រុមហ៊ុន កម្មវត្ថុនៃក្រុមហ៊ុន ដើមទុននៃក្រុមហ៊ុន ។ គ្រឹះស្ថានពាណិជ្ជកម្មនីមួយៗដែលជាកម្មវត្ថុនៃការចុះអត្តលេខសំគាល់ដោយឡែក ត្រូវបានចុះលើសន្លឹកមួយទាំងសងខាង ហើយនៅលើសន្លឹកនោះ មន្ត្រីចុះបញ្ជីពាណិជ្ជកម្មត្រូវចារលេខប្រតិវេទន៍ដើមនៃការសុំចុះបញ្ជីនោះ ។

មាត្រា៣២ថ្មី .- បើមានពាក្យសុំឲ្យចុះនិទ្ទេសដែលបង្កឲ្យលុបចោលនិទ្ទេសដែលមានស្រាប់ មន្ត្រីចុះបញ្ជីពាណិជ្ជកម្មត្រូវគូសលុបនិទ្ទេសនេះ ដោយទឹកខ្មៅក្រហម ឬលុបផ្នែកចំណាំតាមកម្មវិធីកុំព្យូទ័រ ដោយមានសរសេរបង្ហាញនៅរឹមទំព័រនូវសេចក្តីយោងនៃនិទ្ទេសថ្មី និងលេខ ដែលឋិតក្រោមលេខនេះ ប្រតិវេទន៍ ឬពាក្យសុំចុះនិទ្ទេសនោះ ត្រូវបានចុះបញ្ជីដោយពិតប្រាកដ ។

មាត្រា៣៣ថ្មី .- បើសិនមានការលុបឈ្មោះចេញពីបញ្ជី ការលុបនេះត្រូវធ្វើឡើងដោយបន្ទាត់ក្រហមពីរខ្វែងគ្នា ឬលុបតាមវិធីកុំព្យូទ័រ ។

សេចក្តីសំរេចលុបឈ្មោះចេញពីបញ្ជីដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឬពាក្យសុំឲ្យលុបឈ្មោះនោះ ត្រូវចំលងសរសេរនៅលើរឹមទំព័រដោយទឹកខ្មៅក្រហមផងដែរ ។

មន្ត្រីចុះបញ្ជីពាណិជ្ជកម្មបញ្ជាក់និទ្ទេសនេះ ដោយចុះហត្ថលេខាសង្ខេប ។

មាត្រា៣៤ថ្មី .- កាលបើនិទ្ទេសដែលមានក្នុងប្រតិវេទន៍ ត្រូវបានកត់ត្រាបញ្ចូលទៅក្នុងបញ្ជីវិភាគ មន្ត្រីចុះបញ្ជីពាណិជ្ជកម្មត្រូវប្រគល់ជូនអ្នកដែលយកមកតំកល់ទុកនូវប្រតិវេទន៍ មួយច្បាប់ ដែលមានចុះហត្ថលេខាត្រឹមត្រូវសំរាប់ប្រើប្រាស់ជាវិញ្ញាបនប័ត្រចុះឈ្មោះ ។

សន្លឹកប្រតិវេទន៍ទាំងអស់ ដែលរក្សាទុកនៅទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ត្រូវមន្ត្រីចុះបញ្ជីពាណិជ្ជកម្មចងក្រងតាមលេខរៀងយ៉ាងហោចណាស់មួយដងក្នុងមួយឆ្នាំ ។

**មាត្រា៣៥ថ្មី .-** បញ្ជីកាលប្បវត្តិ និងបញ្ជីវិភាគីត្រូវបានរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មជាអ្នកបង់លេខ ចុះហត្ថលេខាសង្ខេប និងពិនិត្យបញ្ជាក់នៅពេលផុតខែម្តងៗ ។ ការពិនិត្យ បញ្ជាក់នេះត្រូវមានបោះត្រារបស់ក្រសួងពាណិជ្ជកម្ម និងចុះហត្ថលេខារបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

បើរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មបញ្ជាក់ថាប្រតិវេទន៍ពាណិជ្ជកម្មពុំបានគោរពតាមការណ៍ដែលមានចែងក្នុងមាត្រា៥០ថ្មី និងមាត្រា៥១ នៃច្បាប់នេះ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មត្រូវប្តឹងអំពីរឿងនេះ ទៅព្រះរាជអាជ្ញាអមតុលាការ មានសមត្ថកិច្ច ។

**មាត្រា៣៦ថ្មី .-** ការចុះឈ្មោះ ការលុបឈ្មោះ ឬការចេញវិញ្ញាបនប័ត្រផ្សេងៗជាភារៈផ្ទាល់របស់មន្ត្រីចុះបញ្ជីពាណិជ្ជកម្ម ។ វិញ្ញាបនប័ត្រទាំងនេះ ត្រូវចេញឲ្យអ្នកសុំពីសៀវភៅបញ្ជីមានលេខ ។ អាករលើកិច្ចការចុះឈ្មោះ លុបឈ្មោះ ឬចេញវិញ្ញាបនប័ត្រផ្សេងៗ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើសំណើរួមគ្នាដោយមន្ត្រីចុះបញ្ជីពាណិជ្ជកម្ម សំរាប់បង់ចូលថវិកាជាតិ ។

**មាត្រា៣៧ថ្មី .-** សេចក្តីចំលងនៃការចុះឈ្មោះក្នុងបញ្ជី ការលុបឈ្មោះចេញពីបញ្ជី និងវិញ្ញាបនប័ត្របញ្ជាក់ពីការគ្មានចុះឈ្មោះចេញដោយមន្ត្រីចុះបញ្ជីពាណិជ្ជកម្ម ត្រូវផ្តល់ជូនដោយឥតគិតថ្លៃតាមពាក្យសុំរបស់អាជ្ញាធរតុលាការ ឬរដ្ឋបាលការ លុះត្រាតែការចុះនិទ្ទេសពីកន្លែងអ្នកទទួលលើនិតនោះ ។

**មាត្រា៣៨ថ្មី .-** រាល់ការចុះឈ្មោះក្នុងបញ្ជី និងលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម ត្រូវបានចុះផ្សាយដោយមន្ត្រីចុះបញ្ជីពាណិជ្ជកម្មក្នុងរាជកិច្ច ។ និទ្ទេសដែលត្រូវចុះផ្សាយមានដូចខាងក្រោមនេះ :

ក-ចំពោះពាណិជ្ជករ

១- លេខចុះបញ្ជី

២- នាមត្រកូល នាមខ្លួន រហស្សនាម ព្រមទាំងនាមសហព័ន្ធ

៣- សកម្មភាព ទីកន្លែង ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើមសកម្មភាព

៤- ផ្លាកសញ្ញា ។

ខ-ចំពោះក្រុមហ៊ុន

១- លេខចុះបញ្ជី

២- នាមករណ៍

៣- ចំនួនដើមទុន

៤- ទីស្នាក់ការ

៥- សកម្មភាព និងថ្ងៃ ខែ ឆ្នាំចាប់ផ្តើម

៦- ទ្រង់ទ្រាយក្រុមហ៊ុន ។

**មាត្រា៤០ថ្មី.-** ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី (ប្រាំម៉ឺន) ៥០.០០០រៀល ទៅ(ប្រាំសែន) ៥០០.០០០រៀល ចំពោះ :

១- រាល់ពាណិជ្ជករ ឬរាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណា ដែលមិនបានចុះបញ្ជីពាណិជ្ជកម្មតាមការបញ្ញត្តិ ។

២- រាល់ពាណិជ្ជករ ឬរាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណា ដែលបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មហើយ តែមិនបានចុះនៅលើវិក្កយបត្រ លិខិតស្នាម ក៏ដូចជាបញ្ជាទិញ ព្រមទាំងលើឯកសារផ្សព្វផ្សាយរបស់ពីទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្ម ដែលខ្លួនបានចុះឈ្មោះនិងលេខដែលខ្លួនបានចុះក្នុងបញ្ជីពាណិជ្ជកម្ម ។

**មាត្រា៤២ថ្មី .-** រាល់ពាណិជ្ជករ ឬរាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណា ដែលបានផ្តល់នូវព័ត៌មានមិនពិតដោយចេតនាអាក្រក់ ដើម្បីនឹងសុំចុះលេខ ឬសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពីមួយឆ្នាំ (១ឆ្នាំ) ទៅប្រាំឆ្នាំ (៥ឆ្នាំ) និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី មួយលាន (១.០០០.០០០) រៀល ទៅដប់លាន (១០.០០០.០០០) រៀល ។

ក្នុងករណីដែលមានការផ្លាស់ប្តូរកែប្រែព័ត៌មានដូចបានចែងក្នុងមាត្រា ១៥ ចំណុច១ មាត្រា១៨ ចំណុច១ និងមាត្រា២០ រាល់ពាណិជ្ជករ ឬអ្នកដឹកនាំក្រុមហ៊ុនណាដែលមិនបានបំពេញបែបបទនៅទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ក្នុងរយៈពេលដប់ប្រាំថ្ងៃ (១៥ថ្ងៃ) ក្រោយពីមានការផ្លាស់ប្តូរ កែប្រែនេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីប្រាំសែន (៥០០.០០០) រៀល ទៅមួយលាន (១.០០០.០០០) រៀល ។

**មាត្រា៤៤ថ្មី .-** ក្នុងករណីមិនរាងចាល ការផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ៤០ថ្មី វាក្យខ័ណ្ឌទី១ នៃមាត្រា៤២ថ្មី មាត្រា៤៣ ត្រូវអនុវត្តកំរិតអតិបរមា ហើយបើមានបទល្មើស ដែលបានចែងក្នុងវាក្យខ័ណ្ឌទី២ នៃមាត្រា ៤២ថ្មី មិនរាងចាលនោះ រាល់ពាណិជ្ជករ ឬអ្នកដឹកនាំក្រុមហ៊ុនត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពីបីខែ (៣ខែ) ទៅមួយឆ្នាំ (១ឆ្នាំ) ។

**មាត្រា៥៤ថ្មី .-** ក្នុងរយៈកាលដែលព្រះរាជាណាចក្រកម្ពុជានៅមិនទាន់មានតុលាការពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្មត្រូវរៀបចំថែរក្សាច្បាប់ចំលងនៃសៀវភៅបញ្ជីពាណិជ្ជកម្ម និង ច្បាប់ដើមនៃរាល់ឯកសារដែលពាក់ព័ន្ធនឹងការចុះបញ្ជីពាណិជ្ជកម្ម ការលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម រហូតដល់តុលាការពាណិជ្ជកម្មត្រូវបានបង្កើតឡើង ។

**មាត្រា៥៧ថ្មី .-** (មាត្រា ៥៨ចាស់)

រាល់ពាណិជ្ជករ និងរាល់ក្រុមហ៊ុនពាណិជ្ជកម្ម ដែលបានធ្វើសកម្មភាពមុនការប្រកាសឱ្យប្រើច្បាប់នេះ ត្រូវប្តឹងសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជ

កម្ម ក្នុងរយៈពេលប្រាំមួយខែ(៦ខែ) ។ បើមានការចាំបាច់ក្រសួងពាណិជ្ជកម្មអាចសំរេចបន្តរយៈពេលនេះបានប្រាំមួយខែ (៦ខែ) ទៀត ។

**មាត្រា៥៨ថ្មី .-** (មាត្រា ៥៩ចាស់)

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៥៩ថ្មី .-** (មាត្រា ៦០ចាស់)

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩

ព្រះហស្ថលេខា

**នរោត្តម សីហនុ**

***

**ព្រះរាជក្រម នស/រកម/១១៩៩/១៣**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើជាផ្លូវការនូវច្បាប់ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា

- តាមសេចក្ដីក្រាបបង្គំទូលស្នើសុំអំពីសម្ដេចនាយករដ្ឋមន្ត្រី និងអំពីអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

ប្រកាសឲ្យប្រើ

ច្បាប់ស្ដីពី គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី២ និងដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ ដើម្បីពិនិត្យច្បាប់នេះឲ្យទាន់តាមការកំណត់របស់មាត្រា១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ ហើយដែលក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសថា ស្របតាមរដ្ឋធម្មនុញ្ញកាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ហើយដែលមានសេចក្ដីទាំងស្រុង ដូចតទៅ ៖

# ច្បាប់
# ស្ដីពី
# គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ

## ជំពូកទី១
## អន្តរការិយកម្មធនាគារ និង ហិរញ្ញវត្ថុ

**មាត្រា ១.-** ធនាគារគឺជានីតិបុគ្គល ដែលមាននីតិសម្បទាពិសេសក្នុងការរើសយកប្រតិបត្តិការធនាគារជាមុខរបរប្រក្រតី ។

**មាត្រា ២.-** ប្រតិបត្តិការដែលជាសកម្មភាពធនាគាររួមមាន :

១- ការផ្ដល់ឥណទានគ្រប់ប្រភេទចំពោះសាធារណជន ដោយមានកំរិតបញ្ចូលទាំងឥណទានភតិសន្យា និងការសន្យាតាមហត្ថលេខា ។

២- ការទទួលប្រាក់បញ្ញើមិនមានមុខសញ្ញាប្រើពីសាធារណជន ។

៣- ប្រព្រឹត្តិកម្មនិងការដាក់ឲ្យអតិថិជនប្រើប្រាស់នូវមធ្យោបាយទូទាត់ជារូបិយវត្ថុ ឬជារូបិយប័ណ្ណ ។

អង្គភាពណាក៏ដោយ ឲ្យតែអនុវត្តជាប្រក្រតីនូវប្រតិបត្តិការណាមួយក្នុងចំណោមប្រតិបត្តិការទាំង៣ប្រភេទខាងលើនេះ ត្រូវបានចាត់ទុកជាបានធ្វើអាជីវកម្មធនាគារតាមការជាក់ស្ដែង ។

អង្គភាពណា ដែលអនុវត្តតែសកម្មភាពមួយក្នុងចំណោមសកម្មភាពជាមូលដ្ឋាន ទាំង៣នេះ ឬអនុវត្តតែផ្នែកមួយនៃសកម្មភាពពីមួយៗនោះ ត្រូវបានឲ្យឈ្មោះថាជាធនាគារ ឯកទេស ។

មាត្រា៣.- ចំពោះគណនីអតិថិជន ឬសំរាប់ខ្លួនឯងផ្ទាល់ ធនាគារអាចធ្វើបាននូវ :

១- រាល់ប្រតិបត្តិការហិរញ្ញវត្ថុដែលមានចែងក្នុងមាត្រា៤ នៃច្បាប់នេះលើកលែង តែប្រតិបត្តិការធានារ៉ាប់រង ដែលត្រូវកំណត់ដោយច្បាប់ធានារ៉ាប់រងដោយឡែក ។

២- រាល់ប្រតិបត្តិការប្តូរប្រាក់ ។

៣- អន្តរការីកម្ម និងការអនុវត្តន៍រាល់ប្រតិបត្តិការលើមូលប័ត្រដែលអាចយក ជួញដូរបាននៅលើទីផ្សារ ។

៤- រាល់ប្រតិបត្តិការលើឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ ។

៥- សេវាពាណិជ្ជកម្មផលរ៉ែ ឬមានការកំណត់ លើលោហធាតុ និងត្បូងថ្មមានតំលៃ និង វត្ថុធាតុដើម ឬទំនិញ ។

៦- ប្រតិបត្តិការលើសេវាកម្មដទៃទៀត ដែលផ្សារភ្ជាប់នឹងសកម្មភាពចំបងរបស់ខ្លួនដោយ មានការយល់ព្រមពីអាជ្ញាធរអាណាព្យាបាល នៃប្រព័ន្ធធនាគារ ។

មាត្រា ៤.- ធនាគារ ដូចដែលបានកំណត់និយមន័យមកហើយ អាចអនុវត្តសំរាប់ខ្លួនឯងផ្ទាល់ ឬ សំរាប់អតិថិជនរបស់ខ្លួន ដោយផ្ទាល់ឬតាមរយៈការចូលហ៊ុនទៅក្នុងក្រុមហ៊ុនឯកទេស ណាមួយ ឬច្រើននូវប្រតិបត្តិការផ្សេងៗលើមូលប័ត្រ ដែលបង្កើតនូវអន្តរការីកម្ម ហិរញ្ញវត្ថុ ជាអាទិ៍រួមមាន :

១- ការប្រមូលមូលនិធិសំរាប់បរិវិសកម្ម ឬសំរាប់ទិញមូលប័ត្រ តាមបញ្ជារបស់អតិថិជន ជាឯកត្តជន ឬជាក្រុមប្រមូលផ្តុំជាអង្គភាពបណ្តាក់ទុនសមូហភាព ។

២- បរិវិសកម្ម និងការជួញដូរមូលប័ត្រ ។

៣- ការរក្សាទុកមូលប័ត្រ ។

៤- ការគ្រប់គ្រងមូលប័ត្រ ជាឯកត្តជនឬជាសមូហភាព ។

៥- ការទិញផ្តាច់មូលប័ត្រនៅពេលផ្សាយចេញ ។

៦- វិស្វកម្មហិរញ្ញវត្ថុ ។

៧- ការផ្តល់ជូនឧបករណ៍និស្សន្ទទាក់ទងនឹងសកម្មភាពរបស់ខ្លួន ។

៨- ប្រតិបត្តិការគ្រប់ប្រភេទលើមូលប័ត្រធ្វើឡើងសំរាប់ខ្លួនផ្ទាល់ក្នុងនាមជាក្រុមហ៊ុនពាណិជ្ជកម្ម ចំណុះច្បាប់ទូទៅ និងបទប្បញ្ញត្តិជាធរមាន ។

មាត្រា ៥.- សំរាប់តតិយជន ក្រុមហ៊ុនហិរញ្ញវត្ថុឯកទេសឯទៀតក៏អាចធ្វើប្រតិបត្តិការលើមូលប័ត្រ ដូចធនាគារដែរ ។

**មាត្រា ៦.-** ទាក់ព័ន្ធនឹងអាជ្ញាប័ណ្ណ ក្រុមហ៊ុនហិរញ្ញវត្ថុត្រូវស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជាស្របតាមបទប្បញ្ញត្តិនៃមាត្រា៧ ចំណុច៩ និងចំណុច១១ និង មាត្រា ៣៣ នៃច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ ជស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ។

ប៉ុន្តែរាល់ប្រតិបត្តិការលើមូលប័ត្រដែលអនុវត្តដោយធនាគារ និងដោយក្រុមហ៊ុនហិរញ្ញវត្ថុ ក៏ត្រូវស្ថិតនៅក្រោមការឃ្លាំមើលរបស់គណៈកម្មការពិសេសមួយដោយឡែក ចំពោះការចេញផ្សាយ តម្លាភាពនៃការជួញដូរ និងកិច្ចការពារប្រាក់សន្សំវិនិយោគក្នុងសន្ធារឹមប័ណ្ណ ។

សមាសភាពនិងតួនាទីរបស់គណៈកម្មការនេះត្រូវបានកំណត់នៅក្នុងច្បាប់ និងបទបញ្ញាដែលគ្រប់គ្រងទីផ្សារហិរញ្ញវត្ថុ ។

**មាត្រា ៧.-** អាជ្ញាធរអាណាព្យាបាលនៃប្រព័ន្ធធនាគារនិងអាជ្ញាធរអាណាព្យាបាលនៃប្រព័ន្ធ ហិរញ្ញវត្ថុត្រូវសហការក្នុងការកំណត់បែបបទ សេវាកម្មភាគមូលប័ត្រ ឬក្នុងឱកាសដែលចេញអាជ្ញាប័ណ្ណ ឬតាមការចេញបទបញ្ជា ដើម្បីជៀសវាងការក័ន្លត្រួត ដែលអាចកើតមានឡើងពីសកម្មភាពជាន់គ្នាមួយចំនួន នៅក្នុងវិស័យធនាគារឬនៅក្នុងវិស័យក្រុមហ៊ុន ហិរញ្ញវត្ថុឯកទេស ដូចជាការប្រមូលប្រាក់បញ្ញើមានមុខសញ្ញា ការរក្សាទុក ឬការគ្រប់គ្រងមូលប័ត្រ ។

**មាត្រា ៨.-** រាល់ប្រតិបត្តិការដែលប្រហាក់គ្នានឹងសកម្មភាពធនាគារ ដូចមានចែងនៅក្នុង មាត្រា ៣ កថាខណ្ឌ២ ៣ ៤ និង៥ នៃច្បាប់នេះ អាចធ្វើឡើងបានដោយអង្គភាព មិនមែនធនាគារ តែក្នុងលក្ខខណ្ឌដែលមានកំណត់ ដោយអាជ្ញាធរអាណាព្យាបាល ប្រសិន បើប្រតិបត្តិការទាំងនោះធ្វើសំរាប់សាធារណជន ។

## ជំពូកទី២
## ដែននៃការអនុវត្តន៍

**មាត្រា៩.-** រាល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដូចដែលបានកំណត់ក្នុងជំពូកទី១ខាងលើ ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ និងត្រូវបានហៅថា "គ្រឹះស្ថានចំណុះច្បាប់នេះ" ក្នុងមាត្រាបន្តបន្ទាប់ទៅនេះ ។

ក្រៅពីគ្រឹះស្ថានចំណុះច្បាប់នេះ នីតិបុគ្គលឬរូបវន្តបុគ្គលណាក៏ដោយត្រូវបានហាមឃាត់មិនឲ្យយកប្រតិបត្តិការធនាគារធ្វើជាអាជីវកម្មប្រក្រតី ។

ក្រៅពីគ្រឹះស្ថានចំណុះច្បាប់នេះ នីតិបុគ្គលឬរូបវន្តបុគ្គលណាក៏ដោយ មិនត្រូវប្រើប្រាស់នូវនាមករណ៍ឬហៅឈ្មោះ ឬពាណិជ្ជសញ្ញា ឬសេវាសញ្ញា ការផ្សាយពាណិជ្ជកម្មឬរាល់សំនួនពាក្យដទៃទៀត ដែលនាំឲ្យមានការយល់ច្រឡំថាខ្លួនត្រូវបានប្រតិគ្រូតឲ្យធ្វើសកម្មភាពណាមួយក្រោមការអនុញ្ញាត នៃច្បាប់នេះ ។

មាត្រា ១០.- បណ្ដាគ្រឹះស្ថានចំណុះច្បាប់នេះ ក្រៅពីត្រូវស្ថិតនៅក្រោមច្បាប់ពាណិជ្ជកម្ម ឬក្រោមលក្ខន្តិកៈនីត្យានុកូលពិសេសនៃក្រុមហ៊ុនមិនមែនពាណិជ្ជកម្ម ត្រូវស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់នេះថែមទៀត ។

## ជំពូកទី៣

## រូបភាពគតិយុត្តរបស់គ្រឹះស្ថានចំណុះច្បាប់នេះ

មាត្រា ១១.- គ្រឹះស្ថានចំណុះច្បាប់នេះត្រូវតែបានបង្កើតឡើង ក្រោមរូបភាពជាក្រុមហ៊ុនភាគហ៊ុន នៃច្បាប់ពាណិជ្ជកម្មឬក្រោមរូបភាពជាក្រុមហ៊ុនមិនមែនពាណិជ្ជកម្ម សង្គមសមាគម ឬសហករណ៍ ដែលស្ថិតនៅក្រោមលក្ខន្តិកៈនីត្យានុកូលដោយឡែក ។

ក្រុមហ៊ុនមិនមែនពាណិជ្ជកម្ម សង្គមសមាគម ឬសហករណ៍ ត្រូវតែបានប្រមូលផ្ដុំគ្នាជាសម្ព័ន្ធ ដែលហៅថាអង្គការកណ្ដាល ។

អង្គការកណ្ដាលទាំងនេះ ត្រូវទទួលបន្ទុកក្នុងការធ្វើឲ្យមានសាមគ្គីភាពរវាងបណ្ដាញនៃគ្រឹះស្ថាន ដែលចូលជាសមាជិក ហើយធានាដំណើរការឲ្យបានត្រឹមត្រូវ ។

ដើម្បីសម្រេចតាមបំណងខាងលើ អង្គការកណ្ដាលទាំងនេះត្រូវចាត់វិធានការចាំបាច់ជាអាទិ៍ ដើម្បីធានាឲ្យមានសាច់ប្រាក់ងាយស្រួលនិងសាធនភាពនៃគ្រឹះស្ថាននីមួយៗនៃបណ្ដាញទាំងមូល ។

អង្គការកណ្ដាលខ្លួនឯងទាំងនេះ ក៏ត្រូវបានចាត់ទុកជាគ្រឹះស្ថានចំណុះច្បាប់នេះដែរ ។

មាត្រា ១២.- គ្រឹះស្ថានចំណុះច្បាប់នេះ ដែលមានទីតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា អាចជាក្រុមហ៊ុនក្រោមច្បាប់ក្នុងស្រុក ឬជាសាខារបស់ធនាគារបរទេស ។

មាត្រា ១៣.- ធនាគារបរទេសអាចបើក នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាបាន នូវការិយាល័យ ដែលមានសកម្មភាពខាងព័ត៌មាន សម្ព័ន្ធការ ឬជាតំណាង បន្ទាប់ពីបានទទួលការអនុញ្ញាតជាមុនពីអាជ្ញាធរអាណាព្យាបាល ។ ប៉ុន្តែ ការិយាល័យទាំងនេះមិនអាចធ្វើប្រតិបត្តិការអន្តរការិយកម្មធនាគារ ឬហិរញ្ញវត្ថុ និងការស្វែងរកអតិថិជនបានឡើយ ។

ការបោះទីតាំងទាំងនោះ អាចប្រកាន់យកទម្រង់ជាក្រុមហ៊ុននៃច្បាប់ក្នុងស្រុក ឬជាគ្រឹះស្ថានសាមញ្ញ ឬជាអ្នកទទួលសិទ្ធិប្រទានសាមញ្ញ ហើយត្រូវតែមានការចុះក្នុងបញ្ជីពាណិជ្ជកម្មតាមរូបភាពដែលប្រកាន់យក ។

ការិយាល័យតំណាងទាំងនេះអាចប្រព្រឹត្តទៅក្រោមនាមករណ៍ ឬហៅឈ្មោះនៃធនាគារបរទេស ដែលខ្លួនតំណាងឲ្យ ។

ការអនុញ្ញាតឲ្យបើកការិយាល័យតំណាងមានថេរវេលាពីរឆ្នាំ (២ឆ្នាំ) ហើយអាចត្រូវបន្តឲ្យបានតែម្តងគត់ ។

## ជំពូកទី៤
## អាជ្ញាប័ណ្ណរបស់គ្រឹះស្ថានចំណុះច្បាប់នេះ

មាត្រា ១៤.- មុននឹងធ្វើសកម្មភាព គ្រឹះស្ថានចំណុះច្បាប់នេះត្រូវទទួលបានអាជ្ញាប័ណ្ណពីអាជ្ញាធរអាណាព្យាបាលសិន ។ មុននឹងផ្តល់អាជ្ញាប័ណ្ណឲ្យ អាជ្ញាធរអាណាព្យាបាលត្រូវពិនិត្យឲ្យបានច្បាស់លាស់ ជាពិសេសនូវ :

១- គុណភាពនៃអ្នកចូលហ៊ុន និងស្ថានភាពពិតប្រាកដខាងហិរញ្ញវត្ថុរបស់អ្នកទាំងនោះ ។

២- សម្បទានៃអ្នកចូលហ៊ុនសំខាន់ៗ ដើម្បីធានារួមគ្នានូវកាតព្វកិច្ចដែលត្រូវផ្តល់អ្នកទាំងនោះក្នុងករណីចាំបាច់ត្រូវការពង្រឹងបន្ថែម តាមវិធីណាមួយ នូវមូលនិធិផ្ទាល់របស់ធនាគារតាមតម្រូវការមាត្រា ២៧ នៃច្បាប់នេះ ។

៣- ភាពសមស្របនៃមធ្យោបាយធនធានមនុស្ស បច្ចេកទេស និងហិរញ្ញវត្ថុ ដោយមានកម្មវិធីសកម្មភាពភ្ជាប់ជាមួយ ។

អាជ្ញាធរអាណាព្យាបាលត្រូវស្វែងយល់ពីគតិមាននៃលក្ខខណ្ឌបដិសិការ ដែល ប្រទេស ប្រៀបផ្តល់ឲ្យការបើកភាពឧត្តមិកៈរបស់ក្រុមហ៊ុនក្រោមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ឬទីស្នាក់ការនៃសកលនាជាអាណិកជន នៃប្រទេសទាំងនោះ ។

មាត្រា ១៥.- អាជ្ញាធរអាណាព្យាបាលនឹងសម្រេចផ្តល់អាជ្ញាប័ណ្ណក្នុងរយៈពេលប្រាំមួយខែ (៦ខែ)គិតចាប់ពីថ្ងៃបានទទួលពាក្យស្នើសុំដែលមានសំណុំលិខិតគ្រប់គ្រាន់ ។ រាល់ការបដិសេធមិនផ្តល់អាជ្ញាប័ណ្ណត្រូវតែមានធ្វើប្រយោគសំអាងដល់ម្ចាស់សំណើ ។ បញ្ជីឈ្មោះនៃគ្រឹះស្ថានប្រតិបត្តិ ត្រូវចុះផ្សាយក្នុងព្រឹត្តិប័ត្រធនាគារជាតិនៃកម្ពុជា និងក្នុងរាជកិច្ចនៃព្រះរាជាណាចក្រកម្ពុជា និងក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរអាណាព្យាបាល ។

## ជំពូកទី៥
## ដើមទុនអប្បបរមា សាធនភាព

មាត្រា ១៦.- គ្រឹះស្ថានចំណុះច្បាប់នេះដែលបង្កើតឡើងក្រោមរូបភាពក្រុមហ៊ុនពាណិជ្ជកម្ម ឬមិនមែនពាណិជ្ជកម្ម នៃច្បាប់ក្នុងស្រុកទោះក្រោមរូបភាពគតិយុត្តបែបណាក៏ដោយ មុនពេលបានអាជ្ញាប័ណ្ណ ត្រូវមានដើមទុនដំបូងដែលត្រូវបង់គ្រប់ចំនួនទាំងស្រុងយ៉ាងតិចស្មើនឹងចំនួនដែលកំណត់ដោយអាជ្ញាធរអាណាព្យាបាល ។

សាខាទាំងឡាយនៃធនាគារបរទេស មុនពេលបានអាជ្ញាប័ណ្ណ ត្រូវមានទាយជ្ជទានដើមទុនដែលត្រូវបង់គ្រប់ចំនួនទាំងស្រុងស្មើនឹងដើមទុនអប្បបរមា របស់គ្រឹះស្ថានចំណុះច្បាប់នេះ បង្កើតឡើងក្រោមទម្រង់ជាក្រុមហ៊ុន នៃច្បាប់ក្នុងស្រុក ។

ដើមទុនអប្បបរមា និងប្រាក់ដាក់តម្កល់ធានាជាអចិន្ត្រៃយ៍នៅក្នុងបញ្ជីធនាគារជាតិ នៃកម្ពុជា របស់គ្រឹះស្ថានចំណុះច្បាប់នេះ ត្រូវកំណត់ដោយប្រកាសរបស់អាជ្ញាធរអាណាព្យាបាល ។ ប៉ុន្តែចំពោះធនាគារពាណិជ្ជ ចំនួនទឹកប្រាក់នៃដើមទុនអប្បបរមា មិនត្រូវស្ថិតនៅក្រោមកំរិតហាសិបពាន់លានរៀល (៥០.០០០.០០០.០០០រ) ទេ ។

ចំនួនទឹកប្រាក់ខាងលើនេះ ត្រូវគិតតាមអត្រាអន្តរជាតិ អេស.ឌី.អ័រ (SDR) ស្មើនឹងប្រាំពាន់ប្រាំមួយរយដប់ប្រាំមួយរៀល (៥.៦១៦រ) ។

ចំពោះប្រាក់ដែលត្រូវតម្កល់នៅធនាគារជាតិនៃកម្ពុជា ត្រូវកំណត់យ៉ាងតិចចំនួនប្រាំភាគរយ (៥%) នៃចំនួនដើមទុនអប្បបរមាខាងលើ ។

គ្រឹះស្ថានចំណុះច្បាប់នេះដែលបង្កើតឡើងក្រោមទំរង់ជាក្រុមហ៊ុន នៃច្បាប់ក្នុងស្រុក និងក្រោមទំរង់ជាសាខាធនាគារបរទេស ត្រូវបង្ហាញជាអចិន្ត្រៃយ៍ថា បន្ទាប់ពីការដកចេញនូវទ្រព្យសកម្មគ្មានតំលៃ ទ្រព្យសកម្មរបស់ខ្លួនអាចតំលៃលើសពីទ្រព្យអកម្ម ដែលជាចំនួនជំពាក់តតិយជនក្នុងទឹកប្រាក់យ៉ាងតិចស្មើនឹងដើមទុនអប្បបរមា ឬមាសភ្លូទានដើមទុនអប្បបរមា ។

**មាត្រា ១៧.-** គ្រឹះស្ថានចំណុះច្បាប់នេះត្រូវគោរពអនុបាតនៃសាធនៈ ប្រភេទដែលកំណត់ដោយអាជ្ញាធរអាណាព្យាបាល តាមវិបរិណាមនៃបទដ្ឋានអន្តរជាតិ ។ អាស្រ័យទៅតាមទំហំហានិភ័យ គ្រឹះស្ថាន ចំណុះច្បាប់នេះត្រូវតែចំរូវបរិមាណមូលនិធិផ្ទាល់ខ្លួនឲ្យបានសមស្របតាមសមាមាត្រ ។

## ជំពូកទី៦
## សមត្ថភាពនៃអ្នកដឹកនាំ

**មាត្រា១៨.-** គ្មានជនណាម្នាក់អាច :

- ធ្វើជាសមាជិកក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថានប្រតិស្រុត
- គ្រប់គ្រង កាន់កាប់ ឬដឹកនាំដោយផ្ទាល់ ឬតាមរយៈសន្ធានការី ទោះជាក្នុងតួនាទីណាក៏ដោយ
- ចុះហត្ថលេខាក្នុងនាមគ្រឹះស្ថាននោះ ។

ប្រសិនបើជននោះ :

១- ត្រូវបានផ្តន្ទាទោសជាស្ថាពរពីបទ :

- ឧក្រិដ្ឋកម្ម

- ចោរកម្ម ឆបោក ឬរំលោភលើការទុកចិត្ត
- លួចឆក់ឬកេងបន្លំទ្រព្យសាធារណៈក្នុងតួនាទីខ្លួនជាអ្នកទទួលរក្សាបញ្ញើ
- ជំរិតយកមូលនិធិ ឬវត្ថុមានតំលៃ ធ្វើឱ្យមានភាពខូចកេរ្តិ៍ឈ្មោះប្រទេសជាតិ ឬល្មើសលើច្បាប់ប្តូរប្រាក់
- ធ្វើត្រីទ្វិកម្ម
- ការចងការប្រាក់
- ក្លែង ឬ / និងប្រើលិខិតក្លែងក្លាយ ឯកជន ឬសាធារណៈ ។

២- ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពីបទចេញមូលប្បទានប័ត្រគ្មានសំវិធានវត្ថុ ។

៣- ត្រូវបានផ្តន្ទាទោសជាស្ថាពរនៅបរទេស ពីបទឧក្រិដ្ឋ ឬមជ្ឈិម ដែលចែងនៅចំណុច១ និង ២ នៃមាត្រានេះ ។

៤- ត្រូវបានផ្តន្ទាទោសនៅព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេស ពីបទធនក្ស័យផ្ទាល់ខ្លួន ឬការជំរះបំណុលតាមផ្លូវតុលាការ ឬការជំរះទ្រព្យសម្បត្តិ ។

៥- ត្រូវរងវិធានការតាមផ្លូវតុលាការ ដោយការបណ្តេញចេញពីមុខងារសាធារណៈ ។

៦- ត្រូវបានកាន់តំណែងជាអភិបាល ក្នុងការគ្រប់គ្រងនៃគ្រឹះស្ថានចំណុះច្បាប់នេះ ដែលអាជ្ញាប័ណ្ណត្រូវបានដកហូតវិញ ដោយមូលហេតុនៃកំហុសខាងវិន័យ ។

## ជំពូកទី៧

## សមាសភាព អត្តសញ្ញាណកម្មអចិន្ត្រៃយ៍ និងការទទួលខុសត្រូវ នៃភាគីរបស់គ្រឹះស្ថានចំណុះច្បាប់នេះ ដែលបង្កើតឡើង ក្រោមរូបភាពជាក្រុមហ៊ុនមិនមែនពាណិជ្ជកម្ម

**មាត្រា ១៩.-** លក្ខខណ្ឌទាំងឡាយនៃការផ្សំបង្កើតដើមទុន ទោះជាប្រែប្រួលក្តី មិនប្រែប្រួលក្តីនៃគ្រឹះស្ថានចំណុះច្បាប់នេះ ដែលបង្កើតក្រោមរូបភាពក្រុមហ៊ុនមិនមែនពាណិជ្ជកម្ម រួមទាំងអត្តសញ្ញាណកម្មអចិន្ត្រៃយ៍នៃសង្គមិកៈ ឬអ្នកកាន់ភាគហ៊ុន នៃក្រុមហ៊ុនមិនមែនពាណិជ្ជកម្មទាំងនេះ ត្រូវបានកំណត់ដាក់ចែងនៅក្នុងលក្ខន្តិកៈនិតិប្បញ្ញត្តិពិសេសមួយ សំរាប់អនុវត្តលើក្រុមហ៊ុនដែលមានលក្ខណៈសហករណ៍ ឬសង្គមសមាគម ។

អនុលោមតាមមាត្រា ១១ និងចំណុច២ នៃមាត្រា ១៤ នៃច្បាប់នេះ អង្គការកណ្តាលនៃបណ្តាញនីមួយៗគឺជាអ្នកទទួលធានាសាធនភាព និងសាច់ប្រាក់ងាយស្រួលនៃបណ្តាញនេះ ចំពោះតតិយជន អ្នកផ្ញើប្រាក់ ឬឥណទាយក ។

## ជំពូកទី៨

## សមាសភាព អត្តសញ្ញាណកម្មអចិន្ត្រៃយ៍ និងការទទួលខុសត្រូវ នៃភាគទុនិកភាពរបស់គ្រឹះស្ថានចំណុះច្បាប់នេះ ដែលបង្កើតឡើង ក្រោមរូបភាពជាក្រុមហ៊ុនពាណិជ្ជកម្ម

**មាត្រា ២០.-** ភាគទុនិកៈនៃគ្រឹះស្ថានចំណុះច្បាប់នេះ ដែលបង្កើតឡើងក្រោមរូបភាពជាក្រុមហ៊ុនពាណិជ្ជកម្មអាចជារូបវន្តបុគ្គល ឬតាមលក្ខខណ្ឌកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច អាចជានីតិបុគ្គល ដែលភាគទុនិកៈត្រូវមានអត្តសញ្ញាណច្បាស់លាស់ ។

អាជ្ញាធរមានសមត្ថកិច្ចត្រូវតែស្គាល់ជាអាទិ៍ នូវក្រុមហ៊ុនដែលជាភាគទុនិកៈបណ្តាក់បន្តគ្នាពីមួយទៅមួយ ។

**មាត្រា ២១.-** ក្រុមហ៊ុនឬសហគ្រិនដែលមានគ្រឹះស្ថានចំណុះច្បាប់នេះជាកូនសម្ព័ន្ធ ដោយផ្ទាល់ក្តី ឬជាចំណង ចំនួនតិចឬច្រើនក៏ដោយ ក៏ត្រូវចាត់ទុកជាគ្រឹះស្ថានចំណុះច្បាប់នេះដែរ ជាអាទិ៍ ចំពោះការទាក់ទងនឹងអាជ្ញាប័ណ្ណ និងភាពចំណុះក្រោមអាជ្ញាធរមានសមត្ថកិច្ច ។

**មាត្រា ២២.-** គ្រឹះស្ថានចំណុះច្បាប់នេះត្រូវបញ្ជូនឲ្យអាជ្ញាធរមានសមត្ថកិច្ច នៅពេលដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ នូវអត្តសញ្ញាណនៃភាគទុនិកៈរបស់ខ្លួន ដែលមានភាគហ៊ុនស្មើ ឬលើសពីចំនួនប្រាំភាគរយ (៥%) នៃដើមទុន ឬនៃសិទ្ធិបោះឆ្នោតដោយផ្ទាល់ ឬដោយប្រយោល ។

**មាត្រា ២៣.-** រាល់ភាគទុនិកៈឬរាល់ក្រុមភាគទុនិកៈត្រូវធ្វើប្រតិវេទន៍ ជូនទៅអាជ្ញាធរមានសមត្ថកិច្ច ដោយផ្ទាល់ឬតាមរយៈគ្រឹះស្ថានចំណុះច្បាប់នេះ ដែលពាក់ព័ន្ធនឹងការធ្វើលទ្ធកម្ម ឬអនុប្បទានភាគហ៊ុន ដែលជាបច្ច័យនាំដោយផ្ទាល់ឬដោយប្រយោលឲ្យភាគទុនិកៈ ឬក្រុមភាគទុនិកៈនេះទទួលបានឬបាត់បង់ទៅវិញចំនួនប្រាំភាគរយ (៥%) នៃដើមទុនរបស់គ្រឹះស្ថានចំណុះច្បាប់នេះ ឬចំនួនប្រាំភាគរយ (៥%) នៃសិទ្ធិបោះឆ្នោត ។

**មាត្រា ២៤.-**

១- រាល់ភាគទុនិកៈឬរាល់ក្រុមភាគទុនិកៈត្រូវទទួល ដោយផ្ទាល់ឬតាមរយៈគ្រឹះស្ថានពាក់ព័ន្ធចំណុះច្បាប់នេះ នូវការអនុញ្ញាតជាមុនពីអាជ្ញាធរមានសមត្ថកិច្ច ដើម្បីធ្វើលទ្ធកម្មឬអនុប្បទានភាគហ៊ុន ដែលជាបច្ច័យនាំដោយផ្ទាល់ឬដោយប្រយោលឲ្យភាគទុនិកៈ ឬក្រុមភាគទុនិកៈនេះ ៖

ក- ទទួលបានឬបាត់បង់ទៅវិញ ពាក់កណ្តាល មួយភាគបី មួយភាគប្រាំ ឬមួយភាគដប់នៃដើមទុន ឬនៃសិទ្ធិបោះឆ្នោត ។

ខ- ទទួលបានឬបាត់បង់ទៅវិញ នូវសិទ្ធិអំណាចនៃការត្រួតពិនិត្យលើការគ្រប់គ្រងរបស់គ្រឹះស្ថានចំណុះច្បាប់នេះ ។

២- គ្រឹះស្ថានចំណុះច្បាប់នេះ ត្រូវទទួលខុសត្រូវក្នុងការបំពេញទម្រង់បែបបទនៃប្រតិវេទន៍ ឬនៃការអនុញ្ញាត ។

ក្នុងករណីដែលវិធានបែបបទទាំងនេះពុំពេញមិនបានត្រឹមត្រូវ ការបោះឆ្នោតរបស់ភាគទុនិកៈពាក់ព័ន្ធនៅក្នុងមហាសន្និបាតពិសេសត្រូវចាត់ទុកជាមោឃៈជាស្វ័យប្រវត្តិ ដោយមិនចាំបាច់ពិចារណាលើទណ្ឌកម្មពិន័យផ្សេងទៀត ដែលត្រូវអនុវត្តផង ។

មាត្រា ២៥.- ក្រោមបទប្បញ្ញត្តិនៃច្បាប់ពាណិជ្ជកម្ម ស្តីពីចំនួនអប្បបរមានៃភាគហ៊ុនទុនិកៈរបស់ក្រុមហ៊ុនមួយដែលទទួលបរិមាណ នៃការដាក់ទុនដើមម្តងៗក្នុងពេលបើមុននៃគ្រឹះស្ថានចំណុះច្បាប់នេះមិនត្រូវអនុវត្តទេ ។ ប៉ុន្តែនៅក្នុងពេលពិនិត្យពាក្យសុំអាជ្ញាប័ណ្ណ ហើយក្រោយមក នៅពេលផ្តល់ប្រតិវេទន៍ ឬសុំការអនុញ្ញាតដូចកំណត់ដែលបានចែងខាងលើ អាជ្ញាធរអាណាព្យាបាលត្រូវ :

- យកចិត្តទុកដាក់ឲ្យមានវត្តមាននៃភាគទុនិកៈ ដែលមានឥទ្ធិពល
- ផ្ទៀងផ្ទាត់នូវការប្រមូលផ្តុំ ក៏ដូចជាការបំបែកប្រភពនៃដើមទុន ។

ប៉ុន្តែការប្រមូលផ្តុំធំ អាចត្រូវបានទទួលយកក្នុងករណីដែលភាគទុនិកៈពាក់ព័ន្ធគឺជាធនាគារបរទេស ដែលមានស្តង់ដារខ្ពស់ ។

មាត្រា ២៦.- នៅក្នុងន័យនៃច្បាប់នេះ ភាគទុនិកៈត្រូវបានចាត់ទុកជាមានឥទ្ធិពល ចាប់តាំងពីពេលដែលខ្លួនមាន ដោយផ្ទាល់ឬដោយប្រយោល នូវភាគទុនយ៉ាងតិចស្មើនឹងម្ភៃភាគរយ (២០%) នៃដើមទុនឬនៃសិទ្ធិបោះឆ្នោត ឬចាប់តាំងពីពេលដែលខ្លួនទទួលបាននូវសិទ្ធិអំណាចក្នុងការសំរេចពិតប្រាកដ ដោយមូលហេតុជាអាទិ៍នៃការបំបែកប្រភពនៃដើមទុន។

មាត្រា ២៧.- កាលណាស្ថានភាពហិរញ្ញវត្ថុនៃគ្រឹះស្ថានចំណុះច្បាប់នេះមានបញ្ហាខ្វះខាត អាជ្ញាធរអាណាព្យាបាលត្រូវបង្គាប់ដោយផ្ទាល់ទៅភាគទុនិកៈមានឥទ្ធិពល ឲ្យជួយជ្រោមជ្រែងក្នុងការបង្កើនមូលនិធិផ្ទាល់ ធ្វើយ៉ាងណាឲ្យបទដ្ឋានបទបញ្ជា នៃសាធនភាពត្រូវបានគោរព ។

ក្នុងករណីមិនព្រមអនុវត្តតាម ភាគទុនិកៈមានឥទ្ធិពលទាំងនោះត្រូវទទួលទណ្ឌកម្មនានា ដែលបានគ្រោងទុកក្នុងចំណុច ២ នៃមាត្រា ៥៥ នៃច្បាប់នេះ ។ បើមានការដំកល់តារាងតុល្យការ ឥណទាយក ឬអ្នកផ្ញើប្រាក់អាចប្តឹងទៅតុលាការទាមទារឲ្យភាគទុនិកៈមានឥទ្ធិពលបំពេញទ្រព្យអកម្ម ។

## ជំពូកទី៩
## សមាសភាព អត្តសញ្ញាណកម្មអចិន្ត្រៃយ៍ និងការទទួលខុសត្រូវ នៃភាគទុនិកភាពរបស់ទីស្នាក់ការគ្រឹះស្ថានចំណុះច្បាប់នេះ ដែលបង្កើតឡើង ក្រោមរូបភាពជាសាខាធនាគារបរទេស

មាត្រា ២៨.- សាខានៃគ្រឹះស្ថានធនាគារឬហិរញ្ញវត្ថុបរទេស ដែលត្រូវបានប្រតិគ្រាហ៍ឲ្យធ្វើសកម្មភាពធនាគារ ឬហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជូនដំណឹងជាបន្ទាន់ដល់អាជ្ញាធរអាណាព្យាបាល ក្រោមការទទួលខុសត្រូវរបស់ខ្លួន នូវព័ត៌មានអំពីការកែប្រែសមាសភាពនៃភាគទុនិកៈមានឥទ្ធិពលនៃទីស្នាក់ការរបស់ខ្លួន ។

**មាត្រា ២៩.-** អាជ្ញាធរអាណាព្យាបាលអាចពិនិត្យឡើងវិញ នូវអាជ្ញាប័ណ្ណដែលបានចេញឲ្យគ្រឹះស្ថាន បើសិនជាការផ្លាស់ប្តូរដែលលើកឡើងនៅមាត្រា ២៨ នៃច្បាប់នេះ អាចនាំឲ្យប៉ះពាល់ការធានាខាងហិរញ្ញវត្ថុ ឬការទទួលខុសត្រូវរបស់ទីស្នាក់ការនៅបរទេស ។

**មាត្រា ៣០.-** ការលើកស្ដារភាពហិរញ្ញវត្ថុដ៏ធ្ងន់ធ្ងរ គ្រប់ធនាគារមានកាតព្វកិច្ចស្នើទៅទីស្នាក់ការនៅបរទេសឲ្យបង្កើនឡើងវិញនូវចំណែកដើមទុន ដែលមានបញ្ជាក់នៅក្នុងកថាខណ្ឌ ២ នៃមាត្រា ១៦ នៃច្បាប់នេះ ឬកែប្រែការប្រើប្រាស់ទ្រព្យសកម្មឡើងវិញ ។

**មាត្រា ៣១.-** ក្នុងករណីបិទតារាងតុល្យការនៅបរទេស នៃទីស្នាក់ការរបស់គ្រឹះស្ថាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ទ្រព្យសកម្មទាំងអស់នៃគ្រឹះស្ថាននេះត្រូវបានចាត់ទុកជាអាទិភាពសំរាប់សងឲ្យអតិថិជនជានិវាសជន ដែលបានយកមកផ្ញើទុកនូវមូលប័ត្រ សាច់ ឬប្រាក់ និងសំរាប់សងឲ្យឥណទាយក ក្នុងករណីអ្នកជំរះបញ្ជីរបស់គ្រឹះស្ថានទទួលស្គាល់ថាជាសិទ្ធិរបស់អ្នកទាំងនោះក្នុងទ្រព្យសកម្ម នៅពេលកំណត់តារាងតុល្យការនៃទីស្នាក់ការ ។

## ជំពូកទី១០
## ភាគកម្មរបស់គ្រឹះស្ថានចំណុះច្បាប់នេះក្នុងដើមទុន
## នៃក្រុមហ៊ុនពាណិជ្ជកម្មដទៃទៀត

**មាត្រា ៣២.-** ត្រូវបានចាត់ទុកជាភាគកម្ម ក្នុងការអនុវត្តន៍ច្បាប់នេះ គឺភាគកម្មដែលអនុញ្ញាតឲ្យគ្រឹះស្ថានចំណុះច្បាប់នេះកាន់កាប់ ដោយផ្ទាល់ឬដោយប្រយោល នូវចំនួនដប់ភាគរយ (១០%) យ៉ាងតិចនៃដើមទុន ឬនៃសិទ្ធិបោះឆ្នោតរបស់ក្រុមហ៊ុន ដែលគ្រឹះស្ថាននោះបានចូលរួម ។

**មាត្រា ៣៣.-** គ្រឹះស្ថានចំណុះច្បាប់នេះមិនអាចមានភាគកម្មលើសពីដប់ប្រាំភាគរយ (១៥%) នៅក្នុងក្រុមហ៊ុនមួយ ហើយសរុបភាគកម្មក្នុងក្រុមហ៊ុនទាំងនោះមិនអាចលើសពីហុកសិបភាគរយ (៦០%) នៃមូលនិធិផ្ទាល់សុទ្ធរបស់ខ្លួនឡើយ ។

**មាត្រា ៣៤.-** ភាគកម្មនៅក្នុងដើមទុននៃសហគ្រាសនិងក្រុមហ៊ុនដូចខាងក្រោមនេះ មិនត្រូវរងកំរិតភាគរយនីមួយៗ ឬរួមគ្នាដែលមានចែងក្នុងមាត្រា ៣៣ នៃច្បាប់នេះឡើយ :

១- សហគ្រាសមានចរិតឧស្សាហកម្ម អចលនទ្រព្យ ឬពាណិជ្ជកម្មដែលជាសកម្មភាពផ្សារភ្ជាប់ជាមួយអាជីវកម្ម នៃគ្រឹះស្ថានចំណុះច្បាប់នេះ ។

២- ក្រុមហ៊ុនមានចរិតធនាគារឬហិរញ្ញវត្ថុ ក្រោយពីមានប្រតិវេទន៍ ឬការអនុញ្ញាតជាមុនពីអាជ្ញាធរអាណាព្យាបាល តាមបទបញ្ញត្តិ នៃជំពូកទី៨ នៃច្បាប់នេះ ។

៣- ក្រុមហ៊ុនអាជីវកម្មកសិកម្ម ។

មាត្រា ៣៥.- ត្រូវបានចាត់ទុកថាជាក្រុមហ៊ុនមានចរិតធនាគារឬហិរញ្ញវត្ថុ សំរាប់ការអនុវត្តន៍ក្នុងចំណុច ២ នៃមាត្រា ៣៤ នៃច្បាប់នេះ គឺ :

១- គ្រឹះស្ថានចំណុះច្បាប់នេះ ។

២- ក្រុមហ៊ុនហិរញ្ញវត្ថុរួមបញ្ចូលទាំងក្រុមហ៊ុនធ្វើសកម្មភាព ដូចមានចែងក្នុងមាត្រា ៨ នៃច្បាប់នេះ ។

៣- សហគ្រាសដែលប្រកបរបរជាប្រក្រតី នូវប្រតិបត្តិការធនាគារនិងប្រតិបត្តិការហិរញ្ញវត្ថុ នៅបរទេស ។

៤- ក្រុមហ៊ុនធានារ៉ាប់រង ។

មាត្រា ៣៦.- កាលបើភាគទុនិកៈគ្រឹះស្ថានចំណុះច្បាប់នេះជាក្រុមហ៊ុនមានចរិតធនាគារ ឬហិរញ្ញវត្ថុ ឬកាលបើគ្រឹះស្ថានចំណុះច្បាប់នេះខ្លួនឯងកាន់កាប់ ភាគកម្មក្នុងក្រុមហ៊ុនមានចរិតធនាគារ ឬហិរញ្ញវត្ថុ អាជ្ញាធរអាណាព្យាបាលត្រូវទាមទារ សំរាប់ការគណនាមូលនិធិផ្ទាល់សុទ្ធ ដើម្បី ជាមូលដ្ឋានឲ្យអនុបាតប្រុងប្រយ័ត្ន នៃគ្រឹះស្ថានចំណុះច្បាប់នេះ នូវ :

- ការដកចេញនៃភាគកម្ម ដែលគ្រឹះស្ថានក្រោយនេះកាន់កាប់ក្នុងក្រុមហ៊ុនមានចរិតធនាគារ ឬហិរញ្ញវត្ថុ
- ការកាត់បញ្ចូលគ្នាជាមុន នៃតារាងតុល្យការរបស់ចង្កោមក្រុមហ៊ុន នៅពេលដែលភាគកម្មទៅវិញទៅមកនេះមានចំនួនស្មើ ឬលើសពីម្ភៃភាគរយ (២០%) នៃដើមទុនក្រុមហ៊ុនពាក់ព័ន្ធ ។

មាត្រា ៣៧.- ការចូលភាគកម្មដោយគ្រឹះស្ថានចំណុះច្បាប់នេះ ក្នុងដើមទុននីតិបុគ្គលមានចរិតឧស្សាហកម្ម ឬពាណិជ្ជកម្មដែលមានទីស្នាក់ការនៅបរទេស ត្រូវមានការអនុញ្ញាតជាមុនពីអាជ្ញាធរអាណាព្យាបាល ។

## ជំពូកទី១១

## ការបោះទីតាំងនៃគ្រឹះស្ថានចំណុះច្បាប់នេះ

## នៅបរទេស ឬនៅក្នុងព្រះរាជាណាចក្រកម្ពុជា

មាត្រា ៣៨.- ការចូលភាគកម្មនៅបរទេសដោយគ្រឹះស្ថានចំណុះច្បាប់នេះ ក្នុងដើមទុនធនាគារ ឬក្រុមហ៊ុនហិរញ្ញវត្ថុ ព្រមទាំងការបើកសាខាឬការិយាល័យតំណាងនៅបរទេសដោយគ្រឹះស្ថានចំណុះច្បាប់នេះ ត្រូវមានការអនុញ្ញាតជាមុនពីអាជ្ញាធរអាណាព្យាបាល ។

មាត្រា ៣៩.- ការបើកសាខាដោយគ្រឹះស្ថានចំណុះច្បាប់នេះនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានការអនុញ្ញាតជាមុនពីអាជ្ញាធរអាណាព្យាបាល ។

ការចូលរួមភាគកម្មដោយគ្រឹះស្ថានក្រោមច្បាប់នេះ ក្នុងដើមទុនរបស់គ្រឹះស្ថានក្រោមច្បាប់នេះមួយទៀត ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃមាត្រា ១៩ ដល់មាត្រា ២៧ ព្រមទាំងមាត្រា ៣៣ ដល់មាត្រា ៣៥ នៃច្បាប់នេះ ។

## ជំពូកទី១២

## អាជ្ញាធរអាណាព្យាបាល និងអំណាចចេញបទបញ្ជា

**មាត្រា ៤០.-** ធនាគារកណ្តាលបំពេញតួនាទីជាអាណាព្យាបាលលើប្រព័ន្ធធនាគារ និងលើសេវាកម្មការប្តូរប្រាក់ ផ្សាររូបិយវត្ថុ ប្រព័ន្ធទូទាត់អន្តរធនាគារ និងអន្តរការិយកម្មហិរញ្ញវត្ថុ ។

ក្នុងតួនាទីនេះ ធនាគារកណ្តាល :

១- ចេញអាជ្ញាប័ណ្ណ និងកាត់ស្រាយបណ្តឹងតវ៉ាអំពីការចេញអាជ្ញាប័ណ្ណនេះ ។

២- រៀបចំ កាន់កាប់បញ្ជីរៀងធនាគារជាប្រចាំ និងចាត់ចែងផ្សព្វផ្សាយក្នុងប្រព្រឹត្តិបត្រធនាគារជាតិនៃកម្ពុជា និងក្នុងរាជកិច្ចនៃព្រះរាជាណាចក្រកម្ពុជា នូវបញ្ជីរាយនាម ធនាគារ ។

៣- ចេញបទបញ្ជា ដើម្បីអនុវត្តច្បាប់នេះ ដែលអនុញ្ញាតឲ្យកំណត់ឲ្យច្បាស់ជាអាទិ៍ នូវ :

ក- ចំនួនដើមទុនអប្បបរមា និងការយកទៅប្រើក្នុងប្រភេទមូលធនកម្ម ។

ខ- អនុបាតឬមេគុណប្រុងប្រយ័ត្នផ្សេងៗ ដែលពាក់ព័ន្ធជាពិសេសដល់ការធានាភាពងាយស្រួលសាធនភាព ការបែងចែកហានិភ័យ និងការប្រឈមមុខទល់នឹងហានិភ័យនៃការប្តូរប្រាក់ ឬនៃទីផ្សារ ។

គ- វិធីវាយតំលៃសមតុល្យនៃគណនី ។

ឃ- លក្ខខណ្ឌនានា ដែលគេអាចចូលរួមភាគកម្មក្នុងដើមទុនរបស់គ្រឹះស្ថានក្រោមច្បាប់នេះ ឬក្រុមហ៊ុនហិរញ្ញវត្ថុ ។

ង- លក្ខខណ្ឌនានាដែលគ្រឹះស្ថានក្រោមច្បាប់នេះអាចចូលរួមភាគកម្មក្នុងដើមទុន នៃក្រុមហ៊ុនដទៃទៀត ដែលមិនមែនធនាគារ ឬហិរញ្ញវត្ថុ ។

ច- ចំណាត់ថ្នាក់ប្រភេទឥណទាន និងការធ្វើសំវិធានធនចំពោះបំណុលពិបាកទារ ។

ឆ- ប្រព័ន្ធគណនេយ្យធនាគារ និងបទដ្ឋានដែលពាក់ព័ន្ធ ។

ជ- លក្ខខណ្ឌនានា ដែលប្រតិបត្តិការធនាគារឬហិរញ្ញវត្ថុត្រូវបានអនុវត្តចំពោះអតិថិជន ។

ឈ-ការរៀបចំសេវាកម្មអន្តរធនាគារជាអាទិ៍ ការបង្កើតមជ្ឈការនៃព័ត៌មាន នៃហានិភ័យ ឬនៃបំណុលពិបាកទារ ។

ញ- លក្ខខណ្ឌនៃការផ្តល់បដិប្បញ្ញត្តិ តាមករណីនីមួយៗក្នុងលក្ខណៈពិសេស និងបណ្តោះអាសន្ន ។

ឍ- លក្ខខណ្ឌនានា ដែលត្រូវធ្វើប្រតិវេទន៍ជូនឬសុំការអនុញ្ញាតជាមុនពីអាជ្ញាធរអាណាព្យាបាល អំពីការកែប្រែឬការផ្លាស់ប្តូរដែលពាក់ព័ន្ធជាមួយនាមករណ៍ ទំរង់នីតិបុគ្គល ដើមទុន ការដឹកនាំ ការបោះទីតាំង និងសកម្មភាពនៃគ្រឹះស្ថានចំណុះច្បាប់នេះឬនៃទីស្នាក់ការ ប្រសិនបើការបើកសាខាធនាគារបរទេស ។

ណ- ការប្រកបមុខរបរស្វែងរកអតិថិជនក្នុងវិស័យធនាគារ ឬហិរញ្ញវត្ថុ ។

ត- ការកំណត់ដោយពិគ្រោះជាមួយគណៈកម្មការវិជ្ជាជីវៈ នៃគ្រឹះស្ថានចំណុះច្បាប់នេះ នូវវិធាននៃការប្រព្រឹត្តទៅនៃប្រព័ន្ធធានាប្រាក់បញ្ញើ ។

ថ-វិធានអនុវត្តនៃច្បាប់នេះ ដែលទាក់ទងផលវិភាគខុសគ្នាស្តីពីលក្ខន្តិកៈគតិយុត្ត វិសាលភាពនៃបណ្តាញ ឬប្រភេទនៃសកម្មភាពរបស់គ្រឹះស្ថានចំណុះច្បាប់នេះ ។

៤- ចាត់ចែងឲ្យផ្សព្វផ្សាយក្នុងព្រឹត្តិបត្រធនាគារជាតិ និងក្នុងរាជកិច្ចនៃព្រះរាជាណាចក្រកម្ពុជា នូវបទបញ្ញាដែលខ្លួនតែងឡើង ដោយសំអាងលើសិទ្ធិអំណាចរបស់ខ្លួន ។

៥- រៀបចំ តាមដាន ត្រួតពិនិត្យប្រព័ន្ធធនាគារ តាមវិធីពិនិត្យផ្ទៀងផ្ទាត់ជាអចិន្ត្រៃយ៍លើឯកសារ និងតាមវិធីត្រួតពិនិត្យតាមការចុះទៅដល់ទីកន្លែង នៃគ្រឹះស្ថានចំណុះច្បាប់នេះ ។ បើពេលណាចាំបាច់ អាចពង្រីកការត្រួតពិនិត្យដល់ទីកន្លែងនៅក្នុងក្រុមហ៊ុនជាបុគ្គលសម្ព័ន្ធ ឬអង្គភាពដែលជាសម្ព័ន្ធញាតិផងទៀតជាអាទិ៍ ក្រុមហ៊ុនដែលជាភាគទុនិកៈ ។

៦- សម្រេច ឬត្រួតពិនិត្យគ្រប់ប្រព័ន្ធទូទាត់អន្តរធនាគារ ។

៧- អាចទាមទារការផ្តល់ព័ត៌មាន ដែលខ្លួនវិនិច្ឆ័យថាមានប្រយោជន៍ដល់បេសកកម្មរបស់ខ្លួនពីគ្រឹះស្ថានចំណុះច្បាប់នេះ ពីរដ្ឋបាលនានា ពីសវនករគណនី ឬពីគ្រប់នីតិបុគ្គល ឬរូបវន្តបុគ្គលដទៃទៀត ។

៨- អាចសំរេចដាក់ទណ្ឌកម្មវិន័យ ក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៥២ ដល់មាត្រា ៥៤ នៃច្បាប់នេះ ។

មាត្រា ៤១.- បេសកកម្មរបស់អាជ្ញាធរអាណាព្យាបាល គឺ :

១- ចេញឲ្យគ្រឹះស្ថានចំណុះច្បាប់នេះនូវអាជ្ញាប័ណ្ណសំរាប់ធ្វើសកម្មភាពធនាគារ ឬហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រោយពីបានពិនិត្យគ្រប់ជ្រុងជ្រោយនូវហេតុផលគ្រប់យ៉ាង ។

២- ប្រកាសឲ្យប្រើនិងចាត់អនុវត្តវិធានប្រុងប្រយ័ត្ននៃរចនាសម្ព័ន្ធនៃការគ្រប់គ្រង ដែលគ្រឹះស្ថានចំណុះច្បាប់នេះត្រូវប្រតិបត្តិតាម ។

៣- ត្រួតពិនិត្យជាអចិន្ត្រៃយ៍ជាក្រោយ នូវស្ថានភាពនិងដំណើរការរបស់គ្រឹះស្ថានចំណុះច្បាប់នេះ នៅលើឯកសារ និងនៅដល់ទីកន្លែង ។

៤- ស្នើដាក់ទណ្ឌកម្មលើគ្រឹះស្ថានចំណុះច្បាប់នេះ ក្នុងករណីមិនប្រតិបត្តិតាមច្បាប់ ។

៥- ប្តឹងទៅតុលាការ ប្រសិនបើគ្រឹះស្ថានចំណុះច្បាប់នេះមិនប្រតិបត្តិតាមច្បាប់ និងបង្កបញ្ហាធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់គណៈអតិថិជន ។

អ្នកដឹកនាំ និងភាគទុនិកនៃគ្រឹះស្ថានចំណុះច្បាប់នេះ ត្រូវទទួលខុសត្រូវក្នុងការភ័ន្តច្រឡំខាងព្រហ្មទណ្ឌ ក៏ដូចជា ឬការភ័ន្តច្រឡំក្នុងកិច្ចគ្រប់គ្រង កង្វះការត្រួតពិនិត្យផ្ទៃក្នុងរបស់ខ្លួន ដោយអនុលោមតាមបទប្បញ្ញត្តិ នៃមាត្រា ១៤ ១៩ ២៧ និងមាត្រា ៣៤ នៃច្បាប់នេះ ។

## ជំពូកទី១៣
## វិធានការប្រុងប្រយ័ត្ន ការត្រួតពិនិត្យផ្ទៃក្នុង

**មាត្រា ៤២.-** នៅក្នុងលក្ខខណ្ឌកំណត់ឡើងដោយអាជ្ញាធរធនាគារកណ្តាល គ្រឹះស្ថានចំណុះច្បាប់នេះ មានកាតព្វកិច្ចគោរព មិនត្រឹមតែវិធានការនៃគណនេយ្យហិរញ្ញវត្ថុ ដែលមានចែងក្នុងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ប១៩៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងគោរពបទដ្ឋានគ្រប់គ្រងទាំងឡាយ សំរាប់ធានាសាច់ប្រាក់ងាយស្រួល និងសាធនភាពចំពោះអ្នកផ្ញើប្រាក់ និងជាទូទៅ ចំពោះតតិយជន ក៏ដូចចំពោះសមតានៃរចនាសម្ព័ន្ធហិរញ្ញវត្ថុរបស់ខ្លួនទៀតផង ។

ដើម្បីគណនាមូលនិធិផ្ទាល់សុទ្ធ ដែលជាមូលដ្ឋានក្នុងការកំណត់បទដ្ឋានប្រុងប្រយ័ត្ន របស់គ្រឹះស្ថានចំណុះច្បាប់នេះនីមួយៗ អាជ្ញាធរធនាគារកណ្តាលត្រូវដកចេញនូវ :

១- ទ្រព្យគ្មានតំលៃខាងទ្រព្យសកម្ម នៃតារាងតុល្យការរបស់គ្រឹះស្ថាននេះ ។

២- ភាគកម្មទាំងឡាយ ដែលមានចូលក្នុងក្រុមហ៊ុនមានចរិតជាធនាគារ ឬហិរញ្ញវត្ថុព្រមទាំងក្នុងលក្ខខណ្ឌដែលកំណត់តាមបទបញ្ជា នូវការឲ្យខ្ចីគ្រប់ប្រភេទ និងគ្រប់រយៈ ការផ្តល់ដល់ភាគទុនិករបស់គ្រឹះស្ថានចំណុះច្បាប់នេះ ឬអ្នកជាប់ព័ន្ធ ដែលគេបានចុះបញ្ជីនោះ ។

**មាត្រា ៤៣.-** នៅក្នុងលក្ខខណ្ឌកំណត់ដោយអាជ្ញាធរធនាគារកណ្តាល គ្រឹះស្ថានចំណុះច្បាប់នេះ ត្រូវមានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលមានវត្ថុបំណងជាអាទិ៍ :

១- ពិនិត្យបញ្ជាក់ថាប្រតិបត្តិការ ដែលអនុវត្តដោយគ្រឹះស្ថានចំណុះច្បាប់នេះ និងការរៀបចំនីតិវិធីខាងក្នុងនោះត្រឹមត្រូវតាមបទប្បញ្ញត្តិ និងបទបញ្ជាតាមបទដ្ឋាន និងរបៀបប្រើវិជ្ជាជីវៈ និងករណីកិច្ចការគ្រូ ក៏ដូចតាមការតម្រង់ទិស នៃការដឹកនាំទូទៅរបស់គ្រឹះស្ថាន ។

២- ពិនិត្យបញ្ជាក់ថា កំរិតកំណត់អំពីហានិភ័យជាអាទិ៍ នៃបដិភាគ ការប្តូរប្រាក់ អត្រាការប្រាក់ និងទីផ្សារ ត្រូវបានគោរពតាមយ៉ាងហ្មត់ចត់ ។

៣- ប្រុងប្រយ័ត្នចំពោះគុណភាព នៃព័ត៌មានគណនេយ្យ ស្ថិតិ និងហិរញ្ញវត្ថុ ដែលផ្សព្វផ្សាយ នៅក្នុង និងទៅខាងក្រៅ ជាពិសេសចំពោះលក្ខខណ្ឌនៃកិច្ចបញ្ជិកានៃការរក្សាទុក និងលទ្ធភាពប្រើប្រាស់នូវព័ត៌មាននេះ ។

## ជំពូកទី១៤
## ការតព្វកិច្ចគណនេយ្យ ការត្រួតពិនិត្យពីខាងក្រៅ
## ដោយស្នងការគណនី

មាត្រា ៤៤.- បទប្បញ្ញត្តិ នៃច្បាប់ពាណិជ្ជកម្ម ឬនៃលក្ខន្តិកៈនីតិបុគ្គលរបស់ក្រុមហ៊ុនមិនមែនពាណិជ្ជកម្ម ដែលពាក់ព័ន្ធនឹងការបញ្ចប់បញ្ជី ការត្រួតពិនិត្យគណនី ព្រមទាំងការបញ្ជាក់អះអាងលើគណនី ដោយស្នងការគណនី ត្រូវអនុវត្តលើគ្រឹះស្ថានចំណុះច្បាប់នេះ ក្នុងក្របខណ្ឌកំណត់ឡើងដោយអាជ្ញាធរអាណាព្យាបាល ។

មាត្រា ៤៥.- គ្រឹះស្ថានចំណុះច្បាប់នេះ មានកាតព្វកិច្ចតាក់តែង និងផ្សព្វផ្សាយ តាមទម្រង់ដែលកំណត់ ប្រចាំឆ្នាំនូវគណនីរបស់ខ្លួន តាមក្របខណ្ឌកំណត់ឡើងដោយអាជ្ញាធរអាណាព្យាបាល ។

ទន្ទឹមនេះ គ្រឹះស្ថានចំណុះច្បាប់នេះ ត្រូវបង្ហាញជូន អាជ្ញាធរអាណាព្យាបាលដោយទៀងទាត់នូវស្ថានភាពគណនេយ្យ អំពីការអនុវត្តន៍វិធានការប្រុងប្រយ័ត្ននីតិប្បញ្ញត្តិ ឬនៃបទបញ្ជា ។

មាត្រា ៤៦.- ស្នងការគណនីអាចធ្វើប្រតិបត្តិការនៅក្នុងគ្រឹះស្ថានចំណុះច្បាប់នេះបាន លុះត្រាតែមានការអនុញ្ញាតជាមុនពីអាជ្ញាធរអាណាព្យាបាល ។

មុននឹងធ្វើការបញ្ជាក់អះអាងលើគណនី ស្នងការគណនីពិនិត្យសច្ចភាពនៃព័ត៌មានគណនេយ្យដែលមាននៅដំណាច់ការិយបរិច្ឆេទ ក្នុងតារាងតុល្យការ ក្រៅតារាងតុល្យការ ក្នុងគណនីអាជីវកម្ម និងក្នុងតារាងឧបសម្ព័ន្ធ ដែលគេរៀបផ្សព្វផ្សាយ ឬផ្ញើជូនអាជ្ញាធរអាណាព្យាបាល ។

ស្នងការគណនីត្រូវប្តឹងទៅតុលាការ បើសិនជាលោកឃើញថាគ្រឹះស្ថានចំណុះច្បាប់នេះ បានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ ឬនៃបទបញ្ជា ធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍សាធារណជន ។

បន្ទាប់ពីការពិនិត្យ ស្នងការគណនីត្រូវតាក់តែង និងផ្ញើជូនអាជ្ញាធរអាណាព្យាបាល នូវរបាយការណ៍ ដែលបរិយាយពីការកត់សំគាល់របស់ខ្លួន ជាអាទិ៍អំពី :

១- ការបង់ដើមទុន ។

២- វិធីវាយតំលៃសមតុល្យ ។

៣- វិធីច្របាច់បញ្ចូលធាតុតុល្យការ ។

៤- ស្ថានភាពហិរញ្ញវត្ថុ នៃគ្រឹះស្ថានចំណុះច្បាប់នេះ ។

៥- កិច្ចព្រមព្រៀងដែលអាចមានដោយផ្ទាល់ឬដោយប្រយោល ក្នុងការរកចំណូល ណាមួយរវាងគ្រឹះស្ថានចំណុះច្បាប់នេះជាភាគីម្ខាងនិងភាគទុនិកៈ ឬ អ្នកដឹកនាំរបស់ខ្លួនជាភាគីម្ខាងទៀត ។

អាជ្ញាធរអាណាព្យាបាលអាចស្នើសុំពីស្នងការគណនីឲ្យផ្តល់ព័ត៌មានលើសកម្មភាព និងស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានចំណុះច្បាប់នេះ ។

ម្យ៉ាងទៀត អាជ្ញាធរអាណាព្យាបាលអាចបញ្ជូនឲ្យស្នងការគណនី នូវសេចក្តីកត់សំគាល់ របស់ខ្លួនឬសំណើសុំឲ្យពន្យល់ ដែលស្នងការគណនីត្រូវតែឆ្លើយតបជាលាយលក្ខណ៍អក្សរ ។

## ជំពូកទី១៥

## ការសំងាត់វិជ្ជាជីវៈ

**មាត្រា ៤៧.-** ចំពោះបុគ្គលដែលចូលរួម ទោះក្នុងឋានៈណាក៏ដោយនៅក្នុងការគ្រប់គ្រង ការពិនិត្យ ការកាន់កាប់ ឬការត្រួតពិនិត្យផ្ទៃក្នុងឬពីខាងក្រៅនៃគ្រឹះស្ថានចំណុះច្បាប់នេះ ឬចំពោះបុគ្គលឯទៀតដែលធ្វើការងារឲ្យគ្រឹះស្ថានចំណុះច្បាប់នេះ មិនត្រូវបើកបង្ហាញប្រាប់ដល់ជនណាក៏ដោយ នូវព័ត៌មានដែលមានចរិតសំងាត់អំពីសេចក្តីប្រកាស ហេតុការណ៍ ឯកសារលិខិត គណនី ប្រតិបត្តិការនៃឯកតាគណនេយ្យហិរញ្ញវត្ថុដែលខ្លួនបានដឹងតាមរយៈមុខងាររបស់ខ្លួន ។

បុគ្គលទាំងឡាយណា ដែលមិនគោរពតាមកាតព្វកិច្ចទាក់ទងនឹងការរក្សាការសំងាត់វិជ្ជាជីវៈនេះ ត្រូវទទួលទោសដែលចែងក្នុងមាត្រា ៥៥ នៃច្បាប់នេះ ។

ប៉ុន្តែកាតព្វកិច្ចរក្សាការសំងាត់វិជ្ជាជីវៈនេះ មិនអាចយកទៅទាស់នឹងអាជ្ញាធរអាណាព្យាបាល ស្នងការគណនី អភិបាលបណ្តោះអាសន្ន អ្នកជំរះបញ្ជី ក៏ដូចជាអាជ្ញាធរតុលាការដែលចាត់ការក្នុងក្របខ័ណ្ឌនៃនីតិព្រហ្មទណ្ឌ ។

## ជំពូកទី១៦

## សម្ព័ន្ធញាតិរបស់គ្រឹះស្ថានចំណុះច្បាប់នេះ

**មាត្រា ៤៨.-** បន្ថែមលើបទប្បញ្ញត្តិនៃមាត្រា ៤២ នៃច្បាប់នេះ ស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធ ការសហការខាងហិរញ្ញវត្ថុគ្រប់ប្រភេទ ដែលផ្តល់ដោយគ្រឹះស្ថានចំណុះច្បាប់នេះ ទោះតាមរូបភាពណាក៏ដោយ ត្រូវតែស្ថិតនៅក្រោមបទបញ្ជារបស់អាជ្ញាធរអាណាព្យាបាលដែលកំណត់ ម្យ៉ាងត្រូវតែដឹងជាអតិបរមាអំពីការសហការនេះ និងម្យ៉ាងទៀតត្រូវស្ថិតនៅក្នុងកំរិតកំណត់ ការបើបត្តុតាពេកៈត្រូវហាមចាត់ទុកជាភាគីក្នុងសម្ព័ន្ធញាតិ ។

**មាត្រា ៤៩.-** ក្នុងន័យនៃច្បាប់នេះ ត្រូវបានចាត់ទុកជាភាគីក្នុងសម្ព័ន្ធញាតិជាមួយគ្រឹះស្ថានក្រោមច្បាប់នេះ គឺ :

១- បុគ្គលទាំងឡាយដែលកាន់កាប់ដោយផ្ទាល់ឬដោយប្រយោលនូវដប់ភាគរយ (១០%) យ៉ាងតិចនៃដើមទុន ឬនៃសិទ្ធិបោះឆ្នោត ។

២- ក្រុមហ៊ុនទាំងពួង ដែលគ្រឹះស្ថានក្រោមច្បាប់នេះកាន់កាប់នៅក្នុងដើមទុន ដោយផ្ទាល់ ឬ ដោយប្រយោល នូវភាគកម្មយ៉ាងតិចស្មើនឹងដប់ភាគរយ (១០%) នៃដើមទុន ឬ សំលេងយ៉ាងតិចដប់ភាគរយ (១០%) នៃសិទ្ធិបោះឆ្នោត ។

៣- បុគ្គលនានាដែលចូលរួមក្នុងការអភិបាល ការដឹកនាំ ការកាន់កាប់ ឬការត្រួតពិនិត្យផ្ទៃក្នុង ។

៤- ភាគីស្នងការគណនី ។

**មាត្រា ៥០.-** អាជ្ញាធរអាណាព្យាបាលមានសិទ្ធិតម្រូវឲ្យគ្រឹះស្ថានក្រោមច្បាប់នេះ អនុវត្តការកំណត់ការខាងបរិវត្តន៍ តាមនីតិវិធីពិសេស ចំពោះបុគ្គលនានា ដែលអាជ្ញាធរអាណាព្យាបាលចាត់ទុកជាភាគីសម្ព័ន្ធពិសេស ជាអាទិ៍ទាំងពួង ឬបរិវត្តន៍ជាមួយបុគ្គលទាំងឡាយដែលមានចែងក្នុងមាត្រា ៤៩ នៃច្បាប់នេះ ឬចំពោះបុគ្គលបរទេសមានភាគកម្មពិសេសផ្សេងទៀត ដែលមានចែងពុំនៅក្នុងមាត្រា ៤៩ នៃច្បាប់នេះក៏ពិតមែន តែមានឥទ្ធិពលក្នុងការគ្រប់គ្រង ដោយពុំមានការប៉ះពាល់ដើមទុនហួសប្រមាណ ។

## ជំពូកទី១៧
## ការសំអាតប្រាក់

**មាត្រា ៥១.-** ដោយផ្អែកតាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០១៩៧/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៧ គ្រឹះស្ថានក្រោមច្បាប់នេះ ត្រូវតែអនុវត្តក្រោមការទទួលខុសត្រូវរបស់ខ្លួន ដោយត្រូវចាត់គ្រប់វិធានការគ្រប់យ៉ាង កត់អត្តសញ្ញាណឲ្យបានច្បាស់លាស់របស់អតិថិជនទាំងអស់ និងរបស់ប្រតិបត្តិការទាំងឡាយ ដែលធ្វើតាមរយៈខ្លួន ហើយនិងជាពិសេសពិនិត្យមួយដែលអាជ្ញាធរអាណាព្យាបាលបានកំណត់ ហើយតាមដានថែមទៀត ត្រូវរក្សាទុកឯកសារទាំងអស់យ៉ាងតិចឲ្យបានដប់ឆ្នាំ (១០ឆ្នាំ) ។

## ជំពូកទី ១៨
## ទណ្ឌកម្មខាងវិន័យ

**មាត្រា ៥២.-** ប្រសិនបើគ្រឹះស្ថានប្រតិគ្រោះបានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ ឬ នៃបទបញ្ជាស្តីពីសកម្មភាពរបស់ខ្លួន ឬប្រសិនមិនបានធ្វើតាមការដាស់តឿន ឬប្រសិនមិនបានធ្វើតាមអធិបញ្ញា អាជ្ញាធរអាណាព្យាបាលអាចសម្រេចដាក់តាមនីតិវិធីដែលធ្វើចំពោះមុខភាគីខ្លួន នូវទណ្ឌកម្មខាងវិន័យណាមួយដូចខាងក្រោមនេះ :

- ការព្រមាន
- ការស្តីបន្ទោស
- ការហាមធ្វើប្រតិបត្តិការមួយចំនួននិងការកំណត់ព្រំដែនផ្សេងទៀត ក្នុងការធ្វើ សកម្មភាព
- ការព្យួរមុខងារបណ្តោះអាសន្នចំពោះអ្នកដឹកនាំម្នាក់ ឬច្រើននាក់ ដោយមាន ឬដោយគ្មានការតែងតាំងអភិបាលបណ្តោះអាសន្ន
- ការឲ្យលាលែងពីការងារជាស្វ័យប្រវត្តិ ចំពោះអ្នកដឹកនាំម្នាក់ ឬច្រើននាក់ ដោយមាន ឬដោយគ្មានការតែងតាំងអភិបាលបណ្តោះអាសន្ន
- ការដាក់ឲ្យស្ថិតនៅក្រោមការអភិបាលបណ្តោះអាសន្នជាបន្ទាន់
- ការដកហូតអាជ្ញាប័ណ្ណជាស្ថាពរ និងការដាក់ឲ្យជំរះបញ្ជីជាបន្ទាន់ ។

ម្យ៉ាងទៀត អាជ្ញាធរអាណាព្យាបាលអាចសំរេច ឬដោយដាច់ឡែក ឬដោយបន្ថែមលើទណ្ឌកម្មទាំងនេះ នូវការពិន័យជាប្រាក់យ៉ាងច្រើនបំផុតស្មើនឹងដើមទុនអប្បបរមា ដែលតំរូវឲ្យគ្រឹះស្ថាននោះអនុវត្ត ។

មាត្រា ៥៣.- ការតែងតាំងអភិបាលបណ្តោះអាសន្នឬអ្នកជំរះបញ្ជី គឺជាវិធានការប្រញាប់បន្ទាន់ ដែលមានចរិតអភិបាល និងអភិរក្ស ។ ការតែងតាំងនេះត្រូវបានជូនដំណឹងជាផ្លូវការដល់គ្រឹះស្ថានសាមី ហើយមានប្រសិទ្ធភាពអនុវត្តជាបន្ទាន់ ។

មាត្រា ៥៤.- ទណ្ឌកម្មផ្សេងទៀតខាងវិន័យ ដែលមានចរិតជាសីលធម៌ឬជាប្រាក់ពិន័យ គឺជាការសំរេចយុត្តាធិការធ្វើឡើងដោយអាជ្ញាធរអាណាព្យាបាល ដែលជាអ្នកមានសិទ្ធិសំរេចចុងក្រោយបំផុតជាស្ថាពរ ។ ទណ្ឌកម្មទាំងនេះ ត្រូវបានអនុវត្តជាបន្ទាន់ ប៉ុន្តែអាចជាកម្មវត្ថុនៃបណ្តឹងសាទុក្ខបានតែវិធីវិនិច្ឆ័យដោយមូលហេតុខុសខាងច្បាប់ ឬខាងនីតិវិធីនៅចំពោះមុខយុត្តា-ធិការរដ្ឋបាលខ្ពស់បំផុត ។

## ជំពូកទី១៩

## ទណ្ឌកម្មខាងព្រហ្មទណ្ឌ

មាត្រា ៥៥.- ក្រៅពីទណ្ឌកម្មដែលមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់នានា ឬលើសពីលក្ខខណ្ឌនៃក្រមព្រហ្មទណ្ឌ និងក្រមពាណិជ្ជកម្ម ទណ្ឌកម្មខាងក្រោមនេះអាចត្រូវបានអនុវត្តនៅក្នុងន័យនៃច្បាប់នេះ គឺ :

១- បុគ្គលណាមួយ ជាអ្នកដឹកនាំក្តី ក្នុងនាមអង្គភាពក្តី ដែលបានធ្វើប្រតិបត្តិការធនាគារជាវិជ្ជាជីវៈជាប្រក្រតីនិងសំរាប់សាធារណជនដោយគ្មានការអនុញ្ញាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយឆ្នាំ (១ឆ្នាំ) ដល់ប្រាំឆ្នាំ (៥ឆ្នាំ) និងពិន័យជាប្រាក់ពីប្រាំលានរៀល

(៥.០០០.០០០រ) ដល់ពីររយហាសិបលានរៀល(២៥០.០០០.០០០រ) ឬទណ្ឌកម្មតែមួយក្នុងចំណោមទណ្ឌកម្មទាំងពីរ ដោយមិនទាន់គិតដល់ការបិទគ្រឹះស្ថានផង ។

២- បុគ្គលណា ឬអង្គភាពណា ដែលបានល្មើសបទប្បញ្ញត្តិនៃមាត្រា ៩ ១១ ១៨ ១៩ ២៧ ៣០ និងមាត្រា ៤៧ នៃច្បាប់នេះ ត្រូវរងទណ្ឌកម្មខាងព្រហ្មទណ្ឌ ដូចមានចែងក្នុងចំណុច ១ នៃមាត្រា ៥៥ នៃច្បាប់នេះ ។

៣- ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពីមួយឆ្នាំ (១ឆ្នាំ) ទៅប្រាំឆ្នាំ (៥ឆ្នាំ) និងពិន័យជាប្រាក់ពីមួយលានរៀល (១.០០០.០០០រ) ដល់ដប់លានរៀល (១០.០០០.០០០រ) ឬអ្នកទទួលទណ្ឌកម្មតែមួយក្នុងចំណោមទណ្ឌកម្មទាំងពីរ ចំពោះបុគ្គលណាម្នាក់ទោះជាស្ថាបនិកក្ដី ឬក្នុងនាមអភិបាលក្ដីដែល :

- បានល្មើសបទប្បញ្ញត្តិនៃមាត្រា ៨ ១៣ ២៣ ២៤ ២៨ ៣៨ ៣៩ ៤៤ ៤៥ ៤៦ និងមាត្រា ៥១ នៃច្បាប់នេះ
- ឬមិនធ្វើតាមនឹងការតម្រូវដែលមានចែងក្នុងចំណុច ៧ នៃមាត្រា៥០ នៃច្បាប់នេះ ពីសំណាក់អាជ្ញាធរអាណាព្យាបាលក្រោយពីការដាស់តឿន
- ឬផ្ដល់ជូនដោយចេតនា នូវព័ត៌មានខុសដល់អាជ្ញាធរអាណាព្យាបាល
- ឬបង្អាក់បង្អង់ ដល់ការត្រួតពិនិត្យដោយអាជ្ញាធរអាណាព្យាបាល ឬដោយស្នងការគណនេយ្យរបស់គ្រឹះស្ថានចំណុះច្បាប់នេះ ព្រមទាំងដល់ការបំពេញបេសកកម្មរបស់អភិបាលបណ្ដោះអាសន្ន ឬអ្នកជំរះបញ្ជី ដែលបានតែងតាំងឡើងដោយអាជ្ញាធរអាណាព្យាបាល ។

**មាត្រា ៥៦.-** ទណ្ឌកម្មដែលមានចែងក្នុងមាត្រា ៥៥ នៃច្បាប់នេះត្រូវសម្រេចដោយតុលាការ ផ្អែកលើពាក្យបណ្ដឹងឬការប្ដឹងទាមទារសិទ្ធិពីបទអាជ្ញា ពីសំណាក់អាជ្ញាធរអាណាព្យាបាល ឬពីសំណាក់សមាគមវិជ្ជាជីវៈរបស់គ្រឹះស្ថានចំណុះច្បាប់នេះ ដែលចែងក្នុងមាត្រា ៧២ នៃច្បាប់នេះ ។

## ជំពូកទី២០

## ការអភិបាលបណ្ដោះអាសន្ន ការជំរះបញ្ជី

**មាត្រា ៥៧.-** ប្រសិនបើមានស្ថានភាពធ្ងន់ធ្ងរ និងជាក់ស្ដែងលើការគ្រប់គ្រងរបស់គ្រឹះស្ថានចំណុះច្បាប់នេះ និងប្រសិនបើការបំពេញបន្ថែមមូលនិធិផ្ទាល់ដែលចែងក្នុងចំណុច ២ នៃមាត្រា ១៤ មាត្រា ១៩ ២៧ និងមាត្រា ៣០ នៃច្បាប់នេះនៅតែគ្មានប្រសិទ្ធភាព អាជ្ញាធរអាណាព្យាបាលអាច ជាស្វ័យប្រវត្តិ ឬតាមសំណើរបស់អ្នកដឹកនាំ ឬរបស់ភាគទុនិក

តែងតាំងអភិបាលបណ្ដោះអាសន្ន សំរាប់រយៈពេលដំបូងដែលមិនអាចលើសពីបីខែ (៣ខែ) ។ ប្រសិនបើកាលៈទេសៈតំរូវ អាណត្តិរបស់អភិបាលបណ្ដោះអាសន្នអាចត្រូវបានពន្យារពេលបីខែ (៣ខែ) ទៀត ។ គ្រឹះស្ថានចំពោះច្បាប់នេះត្រូវទទួលបន្ទុកក្នុងការចេញសោហ៊ុយទាំងអស់ ។

**មាត្រា ៥៨.-** ក្រោយពេលតែងតាំង អភិបាលបណ្ដោះអាសន្នមានសិទ្ធិអំណាចផ្តាច់មុខក្នុងការដឹកនាំការគ្រប់គ្រង និងជាតំណាងឲ្យគ្រឹះស្ថានចំពោះច្បាប់នេះ ។

**មាត្រា ៥៩.-** បេសកកម្មចំបងរបស់អភិបាលបណ្ដោះអាសន្ន គឺ :

- សំរេចជាបន្ទាន់នូវការវាយតំលៃថា គ្រឹះស្ថានចំពោះច្បាប់នេះអាចឬមិនអាចមានសាធនភាព
- គ្រប់គ្រងកិច្ចការប្រចាំថ្ងៃ ដោយការពារឲ្យបានជាអតិបរមានូវសាធនភាពរបស់គ្រឹះស្ថាន និងសមភាពរវាងអ្នកផ្ញើប្រាក់ ឬឥណទាយក ។

**មាត្រា ៦០.-** អភិបាលបណ្ដោះអាសន្ន ត្រូវធ្វើរបាយការណ៍ពីបេសកកម្មរបស់ខ្លួនទៅអាជ្ញាធរអាណា-ព្យាបាល ដើម្បីដកចេញនូវវិធានការសមស្រប បន្ទាប់ពីការវាយតំលៃ គ្រឹះស្ថានត្រូវបានចាត់ទុកថាមានសាធនភាព ហើយគ្រឹះស្ថាននេះអាចគោរពតាមរាល់វិធានការប្រុងប្រយ័ត្នតាមច្បាប់ និងតាមបទបញ្ញា ។

**មាត្រា ៦១.-** ប្រសិនបើបន្ទាប់ពីការវាយតំលៃ គ្រឹះស្ថានអាចមានសាធនភាព ប៉ុន្តែប្រសិនបើគ្រឹះស្ថាននេះ ក្នុងរយៈពេលបីខែ (៣ខែ) គ្មានលទ្ធភាពអនុវត្តវិធានការតាមបទដ្ឋានប្រុងប្រយ័ត្នទាក់ទងនឹងមូលនិធិផ្ទាល់សុទ្ធ និងទាក់ទងនឹងសាច់ប្រាក់ងាយស្រួល អាជ្ញាប័ណ្ណអាចត្រូវដកហូតវិញ ហើយការអភិបាលបណ្ដោះអាសន្នត្រូវបានប្រែក្លាយទៅជាការជំរះបញ្ជីក្រៅផ្លូវតុលាការ ដោយគ្រឹះស្ថានចំពោះច្បាប់នេះ ជាអ្នកទទួលចេញសោហ៊ុយ ។

អ្នកជំរះបញ្ជី ដែលអាចជាអភិបាលបណ្ដោះអាសន្ន ត្រូវជំរះទ្រព្យសកម្ម និងសងបំណុលនៃគ្រឹះស្ថានក្រោមការត្រួតពិនិត្យរបស់អាជ្ញាធរអាណាព្យាបាល ។

**មាត្រា ៦២.-** ប្រសិនបើបន្ទាប់ពីការវាយតំលៃ គ្រឹះស្ថានគ្មានសាធនភាព អាជ្ញាប័ណ្ណត្រូវបានដកហូតភ្លាម ហើយការអភិបាលបណ្ដោះអាសន្ន ត្រូវបានប្រែក្លាយទៅជាការជំរះបញ្ជីតាមផ្លូវតុលាការ ហើយសោហ៊ុយចំណាយជាបន្ទុករបស់គ្រឹះស្ថាន ។

អភិបាលបណ្ដោះអាសន្នត្រូវធ្វើប្រតិវេទន៍នូវការអស់សងប្រាក់ ហើយប្តឹងទៅតុលាការមានសមត្ថកិច្ច ដើម្បីតែងតាំងអ្នកជំរះបញ្ជីតាមផ្លូវតុលាការ ។ អភិបាលបណ្ដោះអាសន្នអាចបំពេញតួនាទីជាអ្នកជំរះបញ្ជីបានដែរ ។

អ្នកជំរះបញ្ជីតាមផ្លូវតុលាការ ជំរះទ្រព្យសកម្ម ហើយដោះស្រាយរាល់កិច្ចសន្យាក្រោមការត្រួតពិនិត្យរបស់តុលាការនិងតាមនីតិវិធីនៃច្បាប់ទូទៅ ។ ប្រតិបត្តិការធនាគារឬហិរញ្ញវត្ថុដែលប្រព្រឹត្តឡើងនៅពេលជំរះបញ្ជី ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ។

មាត្រា ៦៣.- ការជំរះបញ្ជីតាមផ្លូវតុលាការ ឬមិនតាមផ្លូវតុលាការអាស្រ័យដោយគ្រឹះស្ថានចំពោះច្បាប់នេះ គ្មាន ឬ មានសាធនភាព នឹងត្រូវធ្វើឡើងបន្ទាប់ពីការប្រកាសដកអាជ្ញាប័ណ្ណ ដោយការដាក់ទណ្ឌកម្ម ខាងវិន័យ ដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់នេះ ។

មាត្រា ៦៤.- ផ្អែកលើលក្ខណៈពិសេសនៃសកម្មភាពធនាគារឬហិរញ្ញវត្ថុ កិច្ចសន្យាក្នុងតារាងតុល្យការ ឬក្រៅតារាងតុល្យការ បន្ទាប់ពីបានប្រកាសទុកជាបានការ ត្រូវជំរះស្រឡះតាមលំដាប់ដូចខាងក្រោម :

១- សោហ៊ុយនិងចំណាយការដែលពាក់ព័ន្ធដល់ការអភិបាលបណ្ដោះអាសន្ន និងការជំរះបញ្ជីតាមផ្លូវតុលាការ ឬមិនតាមផ្លូវតុលាការ ។

២- ពន្ធ និងអាករ ដែលត្រូវបង់ជូនរតនាគារជាតិ ។

៣- បៀវត្សបុគ្គលិករបស់គ្រឹះស្ថានចំពោះច្បាប់នេះសំរាប់រយៈពេលបីខែ (៣ខែ) មុនថ្ងៃកំណត់តែងតាំងអ្នកជំរះបញ្ជី ។

៤- ឥណទេយ្យធានាដោយឯកសិទ្ធិផ្សេងទៀតឬដោយបុព្វសិទ្ធិភោគ ក្នុងករណីដែលការធានាទាំងនេះ ត្រូវបានព្រមព្រៀងនៅក្រៅរយៈពេលអន្តរាលសង្ស័យ ។

៥- ប្រាក់បញ្ញើជាសាច់ប្រាក់ ជាមាស និងជាមូលប័ត្រ ឬឥណទេយ្យគ្រប់ប្រភេទ ដែលកាន់កាប់ដោយឯកជន ក្រៅពីស្ថាប័នធនាគារឬហិរញ្ញវត្ថុ ដោយចាប់ផ្តើមសងអតិថិជនម្នាក់ៗដែលជាម្ចាស់គណនីប្រាក់បញ្ញើជារៀល នូវទឹកប្រាក់ដូចគ្នាខ្ពស់បំផុតចំនួនពីរលានរៀល (២.០០០.០០០៛) ។

៦- ប្រាក់បញ្ញើផ្សេងទៀតជាសាច់ប្រាក់ ជាមាស និងជាមូលប័ត្រ ឬឥណទេយ្យផ្សេងទៀត ដែលកាន់កាប់ដោយគ្រឹះស្ថានធនាគារ ឬហិរញ្ញវត្ថុ ។

៧- ឥណទេយ្យជាប់លក្ខខណ្ឌ និងការចូលរួមជាប់ភាគភាព ។

មាត្រា ៦៥.- អាជ្ញាធរអាណាព្យាបាល អភិបាលបណ្ដោះអាសន្ន ឬអ្នកជំរះបញ្ជី ត្រូវតែប្តឹងទៅតុលាការ ប្រសិនបើសំគាល់ឃើញមានបទល្មើសធ្ងន់ធ្ងរខាងព្រហ្មទណ្ឌ ដែលជំទាស់នឹងបទប្បញ្ញត្តិច្បាប់ ឬបទបញ្ជា ។

មាត្រា ៦៦.- អភិបាលបណ្ដោះអាសន្នឬអ្នកជំរះបញ្ជី ត្រូវបានជ្រើសរើសដោយអាជ្ញាធរអាណាព្យាបាល នៅក្នុងបញ្ជីអ្នកមានវិជ្ជាជីវៈប្រកបដោយគុណវុឌ្ឍិ ដែលអាជ្ញាធរអាណាព្យាបាលបានរៀបចំជាមួយក្រសួងយុត្តិធម៌ ។

**មាត្រា ៦៧.-** ប្រសិនបើបេសកកម្មខាងលើ ត្រូវរាំងស្ទះតាមរបៀបណាក៏ដោយគ្រឹះស្ថានចំណុះច្បាប់នេះ អភិបាលបណ្តោះអាសន្ននិងអ្នកជំរះបញ្ជី ត្រូវប្រើប្រាស់សិទ្ធិប្តឹងតវ៉ាចំពោះតុលាការ ពីបទល្មើសមិនឲ្យបំពេញមុខងារ ។

**មាត្រា ៦៨.-** ភាពទុនិកៈរបស់គ្រឹះស្ថានចំណុះច្បាប់នេះដែលគេកាត់ក្ស័យធនភាព អាចគេចផុតពីការអនុវត្ត បាតវិសាមញ្ញ នូវការជំរះបញ្ជីគ្រឹះស្ថានរបស់ខ្លួនបានតាមនីតិវិធី នៃច្បាប់ទូទៅ ។

ផ្តើមចេញពីសេចក្តីសំរេចនេះ អាជ្ញាធរអាណាព្យាបាលតែងតាំងអ្នកជំរះបញ្ជីដើម្បីឲ្យធ្វើប្រតិបត្តិការជំរះបញ្ជីក្រោមការត្រួតពិនិត្យរបស់ខ្លួន ។

**មាត្រា ៦៩.-** ចំណាយការ និងសោហ៊ុយផ្សេងៗទៀត ដែលកើតមកពីការអភិបាលបណ្តោះអាសន្ន ឬដោយការជំរះបញ្ជីត្រូវគិតគួរលើមូលដ្ឋាននៃអត្រាតំលៃវិជ្ជាជីវៈប្រចាំសំរាប់ជាចរមាន និងជាបន្ទុកស្វ័យប្រវត្តិរបស់គ្រឹះស្ថានចំណុះច្បាប់នេះ តាមការអនុវត្តន៍មាត្រា ៥៧ ៦១ ៦២ ៦៣ និងមាត្រា ៦៤ នៃច្បាប់នេះ ។

## ជំពូកទី២១

## កិច្ចការពារអតិថិជន

**មាត្រា ៧០.-** អាជ្ញាធរអាណាព្យាបាលមានបន្ទុកកំណត់នូវគំរូវិធាននៃការដឹកនាំ ក្រោយពីការពិគ្រោះយោបល់ពីវិជ្ជាជីវៈ សំដៅការពារអតិថិជន ជាអាទិ៍ចំពោះកិច្ចការ ដែលពាក់ព័ន្ធទៅនឹង :

១- តម្លាភាព និងការកំរិតលក្ខខណ្ឌនៃបរិក្ខាទាននិងតំលៃការនៃប្រតិបត្តិការធនាគារ ឬហិរញ្ញវត្ថុ ។

២- ការអនុវត្តន៍ ឬការបញ្ច្រាសឥណទាន ។

៣- ការចរចាឡើងវិញលើការខ្ចី ។

**មាត្រា ៧១.-** សមតុល្យឥណទាយី នៃគណនីរបស់អតិថិជន ឬរបស់គ្រឹះស្ថានធនាគារ ឬហិរញ្ញវត្ថុ ដែលនៅសល់គ្មានចលនាពីសំណាក់ម្ចាស់គណនី ក្នុងរយៈពេលដប់ឆ្នាំ (១០ឆ្នាំ) ជាប់គ្នា ត្រូវតែផ្ទេរក្រោយពីរយៈពេលនេះ ជូនទៅធនាគារជាតិនៃកម្ពុជា ដែលជាអ្នកទទួលបន្ទុកគ្រប់គ្រងប្រាក់បញ្ញើធនាគារ ដែលត្រូវរងអាជ្ញាយុកាលលេទ្ធកម្ម ។

## ជំពូកទី២២

## ការរៀបចំវិជ្ជាជីវៈ

**មាត្រា ៧២.-** នៅក្រោមរូបភាពគតិយុត្តឬឯកទេសកម្មណាក៏ដោយ គ្រឹះស្ថានចំណុះច្បាប់នេះទាំងអស់ មានកាតព្វកិច្ចចូលជាសមាជិកដោយផ្ទាល់ទៅក្នុងសមាគមវិជ្ជាជីវៈតែមួយគត់ ដែលលក្ខន្តិកៈត្រូវតែដាក់សុំទិដ្ឋាការជាមុន ពីសំណាក់អាជ្ញាធរអាណាព្យាបាល ។ ដោយឡែកចំពោះក្រុមហ៊ុនមិនមែនពាណិជ្ជកម្ម ការចូលជាសមាជិកក្នុងសមាគមវិជ្ជាជីវៈត្រូវធ្វើតាមរយៈអង្គការសហព័ន្ធរួមដូចមានកំណត់ក្នុងមាត្រា ១១ នៃច្បាប់នេះ ។

សមាគមនេះត្រូវស្ថិតនៅក្រោមអំណាចប្រធានតែម្នាក់ ដែលសមាជិកទាំងអស់ត្រូវបោះឆ្នោតជ្រើសរើស តាមនីតិវិធីច្បាស់លាស់ក្នុងលក្ខន្តិកៈរបស់សមាគម ។ ប៉ុន្តែនៅក្នុងផ្ទៃក្នុងនៃសមាគម សមាជិកអាចប្រមូលផ្តុំគ្នា ជាផ្នែករងដាច់ៗគ្នាទៅតាមឯកទេសកម្មវិជ្ជាជីវៈរបស់ខ្លួន ។

មាត្រា ៧៣.- សមាគមវិជ្ជាជីវៈ នេះមានកម្មវត្ថុ ដូចតទៅ :

១- តំណាងផលប្រយោជន៍សមូហភាពរបស់គ្រឹះស្ថានចំពោះច្បាប់នេះ ជាពិសេសចំពោះអំណាចសាធារណៈ និងអាជ្ញាធរអាណាព្យាបាល ។

២- ផ្តល់ព័ត៌មានដល់សមាជិក និងសាធារណជន ស្តីពីទិដ្ឋភាពនៃប្រតិបត្តិការធនាគារ និងហិរញ្ញវត្ថុ ។

៣- សិក្សារាល់បញ្ហាដែលជាប្រយោជន៍រួម ។

៤- លើកកំពស់ការបណ្តុះបណ្តាលអន្តរធនាគារខាងវិជ្ជាជីវៈ ។

៥- រៀបចំ និងគ្រប់គ្រងរាល់សេវាអន្តរធនាគារ ដោយមានការយល់ព្រម ឬក្រោមការត្រួតពិនិត្យពីអាជ្ញាធរអាណាព្យាបាល ។

៦- ប្តឹងទៅតុលាការ យោងតាមមាត្រា ៥៦ នៃច្បាប់នេះ ។

## ជំពូកទី២៣
## អន្តរប្បញ្ញត្តិ

មាត្រា ៧៤.-

១- គ្រឹះស្ថានដែលបានទទួលប្រតិគ្រុតពីមុនមក ត្រូវកែតម្រូវលក្ខន្តិកៈសកម្មភាព និងរចនាសម្ព័ន្ធហិរញ្ញវត្ថុរបស់ខ្លួនឲ្យបានសមស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ក្នុងរយៈពេលប្រាំមួយខែ (៦ខែ) ក្រោយពីច្បាប់នេះចូលជាធរមាន និងត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណជាថ្មីនៅក្នុងរយៈពេលដូចគ្នានេះ ។

ក្រោយពីការពិនិត្យពាក្យសុំ ធនាគារជាតិនៃកម្ពុជានឹងផ្សព្វផ្សាយក្នុងព្រឹត្តិបត្រធនាគារជាតិ និងក្នុងរាជកិច្ចនៃព្រះរាជាណាចក្រកម្ពុជា នូវឈ្មោះគ្រឹះស្ថាន ដែលបានទទួលប្រតិគ្រុតតាមបទប្បញ្ញត្តិ នៃច្បាប់នេះ ។

ក្រោយរយៈពេលប្រាំមួយខែ (៦ខែ) គ្រឹះស្ថានណាដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះនឹងបទដ្ឋានទាំងឡាយសំរាប់អនុវត្ត ត្រូវបញ្ឈប់សកម្មភាពរបស់ខ្លួន និងត្រូវធ្វើការជំរះបញ្ជី ។

២- គ្រឹះស្ថានណាយកប្រតិបត្តិការមានចរិតជាធនាគារ ឬហិរញ្ញវត្ថុធ្វើអាជីវកម្ម ដែលចែងក្នុងមាត្រា ២ មាត្រា ៣ និងមាត្រា ៤ នៃច្បាប់នេះ ដោយគ្មាននីតិសម្បទា ត្រូវបញ្ឈប់ជាបន្ទាន់នូវសកម្មភាពរបស់ខ្លួន ហើយត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណទៅអាជ្ញាធរអាណាព្យាបាលពាក់ព័ន្ធក្នុងរយៈពេលបីខែ (៣ខែ) ចាប់ពីពេលដែលច្បាប់នេះចូលជាធរមាន ។

ឃ- អង្គភាពទាំងឡាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលកំពុងអនុវត្តប្រតិបត្តិការធនាគារសំដៅជំរុញអន្តរការីយកម្មធនាគារ នៅក្នុងវិស័យកសិកម្ម សិប្បកម្ម ជំនួញតូចតាចនិងសេវាចំពោះឯកត្តជន អាចបន្តសកម្មភាពរបស់ខ្លួននៅក្នុងលក្ខខណ្ឌបដិប្បញ្ញត្តិនៃច្បាប់នេះ ដែលត្រូវបានកំណត់ដោយបទបញ្ញត្តិគតិយុត្តរបស់ធនាគារជាតិនៃកម្ពុជា ជាអាទិ៍ពី :

- ដើមទុនអប្បបរមា
- អាជ្ញាប័ណ្ណ និងបែបបទអនុវត្ត
- វិធានការប្រុងប្រយ័ត្ន ដែលត្រូវប្រតិបត្តិតាម
- លក្ខខណ្ឌនៃការបោះទីតាំង ។

## ជំពូកទី២៤

## អវសានប្បញ្ញត្តិ

**មាត្រា ៧៥.-** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧៦.-** ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩

ព្រះហស្តលេខា
**នរោត្តម សីហនុ**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
**ហ៊ុន សែន**

បានជំរាបជូនសម្ដេចនាយករដ្ឋមន្ត្រី
អគ្គទេសាភិបាលធនាគារជាតិកម្ពុជា
ហត្ថលេខា
**ជា ចាន់តូ**

★★★

# ២-ព្រះរាជក្រឹត្យ

## ព្រះរាជក្រឹត្យ នស/រកត/១១៩៩/១៩៧

**យើង**

**ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

*****

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

- យោងតាមសំណើ របស់សម្ដេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ .-** តែងតាំងលោកឧត្តម **សិរិទ្ធ សារុន** ជាទីប្រឹក្សាសម្ដេច **ហេង សំរិន** អនុប្រធានទី១ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ទទួលបន្ទុកសង្គមកិច្ច និងអភិវឌ្ឍន៍ជនបទ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា ២ .-** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល ត្រូវទទួលបន្ទុកអនុវត្តន៍ព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះ តទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩

ព្រះហស្ថលេខា

**នរោត្តម សីហនុ**

★★★

## ព្រះរាជក្រឹត្យ នស/រកត/១១៩៩/១៩៨

**យើង**

**ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

*****

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ អនុក្រឹត្យលេខ ១០១ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មការអភិវឌ្ឍន៍រៀបចំបុណ្យជាតិ-អន្តរជាតិ
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ .- តែងតាំងឥស្សរជនថ្នាក់ដឹកនាំ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ចំនួនពីររូប ដូចខាងក្រោម ៖

១- លោកឧត្តម **មិន ឃិន** ជាអគ្គលេខាធិការ មានឋានៈស្មើ **រដ្ឋលេខាធិការ**

២- លោកឧត្តម **ជា សុខុម** ជាអគ្គលេខាធិការរង មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**

មាត្រា ២ .- រាល់បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ .- នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឲ្យបានសម្រេច ។

មាត្រា ៤ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩

ព្រះហស្តលេខា

នរោត្តម សីហនុ

***

## ព្រះរាជក្រឹត្យ នស/រកត/១១៩៩/១៩៩

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

*****

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ក្រឹត្យលេខ ២៥ ក្រ. ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៨៨

ត្រាស់បង្គាប់

មាត្រា ១ .- ត្រូវបន្ធូរបន្ថយទោសរយៈពេល ០៦ខែ ឲ្យទណ្ឌិតចំនួន ០១នាក់ ដែលបានកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោស :

- ទណ្ឌិតឈ្មោះ ហ៊ាន ម៉ៅខ្លឹង ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៦ឆ្នាំ តាមអំណាចសាលក្រមលេខ ០៦ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ របស់តុលាការយោធា ។

**មាត្រា ២ .-** ព្រះរាជក្រឹត្យនេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**មាត្រា ៣ .-** ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ ក្រសួងយុត្តិធម៌ គណៈកម្មការយោធា ត្រូវអនុវត្តតាមព្រះរាជក្រឹត្យនេះ ឲ្យបានជាស្ថាពរ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩

ព្រះហស្តលេខា

**នរោត្តម សីហនុ**

★★★

# II. រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ៩៩ អនក្រ.បក

### ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតធនាគារអភិវឌ្ឍន៍ជនបទ

***

**រាជរដ្ឋាភិបាល**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញ ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- បានឃើញ អនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រមលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ

- បានឃើញ អនុក្រឹត្យស្តីពីការបង្កើតធនាគារអភិវឌ្ឍន៍ជនបទលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៨
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១ .-** មាត្រា ១ ៣ ៧ ៨ អនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតធនាគារអភិវឌ្ឍន៍ជនបទ ត្រូវបានកែសំរួលដូចខាងក្រោម ៖

**មាត្រា ១ថ្មី :** ធនាគារអភិវឌ្ឍន៍ជនបទ (ធ.អ.ជ) ជាសហគ្រាសសាធារណៈមានទំរង់ជាក្រុមហ៊ុនរដ្ឋ ។ ក្នុងករណីដែលមានការចូលរួមភាគហ៊ុនពីឯកជន ឬពីភ្នាក់ងារជាតិ-អន្តរជាតិ (ធ.អ.ជ) នឹងប្រែក្លាយទៅជាសហគ្រាសសាធារណៈ ដែលមានទំរង់ជាក្រុមហ៊ុនចំរុះរដ្ឋ ។ ធនាគារអភិវឌ្ឍន៍ជនបទមានស្វ័យភាពពេញលេញក្នុងការដឹកនាំគ្រប់គ្រងសកម្មភាពរបស់ខ្លួន ។

**មាត្រា ៣ថ្មី :** ភារកិច្ចចំបងរបស់ធនាគារអភិវឌ្ឍន៍ជនបទរួមមាន :

១- ផ្តល់ហិរញ្ញប្បទាន និងបុនហិរញ្ញប្បទាន ដល់ស្ថាប័នមីក្រូហិរញ្ញវត្ថុទាំងអស់ និងធនាគារពាណិជ្ជដែលមានសកម្មភាពទ្រទ្រង់សេដ្ឋកិច្ចជនបទ ។

២- ធ្វើការចរចាជាមួយម្ចាស់ជំនួយនានា ដើម្បីទាក់ទាញជំនួយ និងឥណទានអនុគ្រោះសំរាប់ពង្រីកសកម្មភាពរបស់ធនាគារ ។

៣- សហការជាមួយស្ថាប័នហិរញ្ញវត្ថុនានា ក្នុងការផ្តល់ឥណទានដល់កសិករ និងសហគ្រាសក្នុងវិស័យកសិកម្មអភិវឌ្ឍន៍ជនបទ និងសេដ្ឋកិច្ចជនបទ ។

៤- ប្រមូលប្រាក់បញ្ញើគ្រប់ប្រភេទ ។

៥- ធ្វើប្រតិបត្តិការធនាគារ ហិរញ្ញវត្ថុឥណទានតូចៗ និងធ្វើសេវាកម្មផ្សេងៗ ។

៦- ផ្តល់ការហ្វឹកហ្វឺនផ្នែកជំនាញដល់បុគ្គលិកប្រតិបត្តិករមីក្រូហិរញ្ញវត្ថុតាមកម្មវិធីគំរោងជំនួយ ។

៧- ក្នុងករណីដែលរាជរដ្ឋាភិបាលបានចាត់ចែងផ្តល់ឥណទាន តាមកម្មវិធីរបស់រាជរដ្ឋាភិបាល ត្រូវទទួលសងចំពោះការខាតបង់របស់ (ធ.អ.ជ) ទាំងស្រុង ។

៨- ក្នុងករណីពិសេស (ធ.អ.ជ) អនុវត្តគំរោងឥណទានតាមសំណើរបស់ម្ចាស់ជំនួយក្នុងកាលៈទេសៈ ដែលប្រតិបត្តិករមីក្រូហិរញ្ញវត្ថុពុំអាចអនុវត្តបានហើយនៅត្រឹមកំរិតមូលនិធិរបស់ម្ចាស់ជំនួយនោះ ។

**មាត្រា ៧ថ្មី :** ធនាគារអភិវឌ្ឍន៍ជនបទ ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិទូលាយ ដើម្បីបំពេញការងារក្នុងក្របខ័ណ្ឌនៃបទបញ្ញត្តិ នៃអនុក្រឹត្យនេះ និងលក្ខន្តិកៈផ្ទៃក្នុងរបស់ខ្លួន ។

ក្រុមប្រឹក្សាភិបាល មានសមាសភាពដូចតទៅ ៖

១- អគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ ០១រូប ជាប្រធាន

២- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១រូប ជាសមាជិក

៣- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ០១រូប ជាសមាជិក

៤- តំណាងអាជីវករក្នុងវិស័យធនាគារ ០១រូប ជាសមាជិក

៥- តំណាងស្ថាប័នមីក្រូហិរញ្ញវត្ថុ ០១រូប ជាសមាជិក

៦- តំណាងក្រសួងអភិវឌ្ឍន៍ជនបទ ០១រូប ជាសមាជិក

៧- តំណាងបុគ្គលិករបស់ ធ.អ.ជ ០១រូប ជាសមាជិកស្វ័យប្រវត្តិ

មាត្រា ៨ថ្មី : ធនាគារអភិវឌ្ឍន៍ជនបទ ត្រូវបានគ្រប់គ្រង និងដឹកនាំដោយប្រធានអគ្គនាយក ០១រូប ដែលតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

សមាជិកក្រុមប្រឹក្សាភិបាលដទៃទៀត លើកលែងតំណាងបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍ជនបទ ត្រូវបានតែងតាំងដោយអនុក្រឹត្យសំរាប់អាណត្តិ ០៣ឆ្នាំ ។ អាណត្តិនេះអាចបន្តទៀតបាន ដោយអនុក្រឹត្យតាមសំណើក្រសួងស្ថាប័ន ដែលខ្លួនតំណាងឲ្យ ។

មាត្រា ២ : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន និងអភិបាលគ្រប់ខេត្ត-ក្រុង មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩

បានជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា
គាត ឈន់

នាយករដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
ហ៊ុន សែន

★★★

## អនុក្រឹត្យ ១០០ អនក្រ.បក
## ស្តីពីការផ្ទេរផលធាន

***

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រម នស/រកម/០១៩៩/០១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩
- បានឃើញ អនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩
- បានឃើញ អនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការផ្ទេរចំណូល និងផ្ទេរឥណទានថវិកា សំរាប់ក្រសួងស្ថាប័នថ្មី
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១ .-** ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកា ចំនួន ១៨៨ លានរៀល (មួយរយប៉ែតសិបប្រាំបីលានរៀល) ពីជំពូក ៩១ (ចំណាយមិនបានគ្រោងទុក) នៃមូលចំណាយមិនទាន់បែងចែក មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការផ្គត់ផ្គង់តូច) របស់ក្រសួងផែនការ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩ ។

**មាត្រា ២ .-** ឥណទានថវិកាក្នុងមាត្រា ១ ខាងលើត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ សំរាប់ចំណាយដំណើរការរដ្ឋបាល ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា
រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
**អ៊ុក រ៉ាប៊ុន**

# អនុក្រឹត្យ ១០១ អនក្រ.បក

## ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ អនុក្រឹត្យលេខ ៤៩ អនក្រ.បក ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការផ្ទេរគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សំរេច

## ជំពូកទី១

## បទបញ្ញត្តិទូទៅ

**មាត្រា ១ .-** អនុក្រឹត្យនេះ កំណត់បេសកកម្មមុខងារ ភារកិច្ចនិងការរៀបចំក្រុមនានារបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

## ជំពូកទី២

## បេសកកម្ម តួនាទី និង ភារកិច្ច

**មាត្រា ២ .-** គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ មានអគ្គលេខាធិការដ្ឋានមួយ ជាអង្គភាពប្រតិបត្តិ ដែលត្រូវបានដឹកនាំ និងគ្រប់គ្រងដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងតាមការចាំបាច់ ។ អគ្គលេខាធិការមានឋានៈស្មើរដ្ឋលេខាធិការ អគ្គលេខាធិការរងមានឋានៈស្មើអនុរដ្ឋលេខាធិការ ។

**មាត្រា ៣ .-** អគ្គលេខាធិការដ្ឋាន នៃគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ មានបេសកកម្មអនុវត្តរាល់ការងាររបស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ តាមការ

ណែនាំ និងការចង្អុលទិសរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។ ក្នុងគោលបំណងនេះ អគ្គលេខាធិការដ្ឋាន មានភារកិច្ចជាអាទិ៍ ៖

- លើកគំរោងផែនការ អំពីរូបភាពចាត់តាំង និងទទួលរៀបចំគ្រប់ពិធីពិធីបុណ្យប្រពៃណីជាតិ បុណ្យជាតិ បុណ្យអន្តរជាតិ និងគ្រប់ទិវាបុណ្យប្រចាំឆ្នាំ ដែលរាជរដ្ឋាភិបាលបោះពុម្ពកំណត់ ដោយត្រូវធានាអត្ថន័យ និងខ្លឹមសារនៃបុណ្យនីមួយៗ ។
- ទទួលបន្ទុកគ្រប់គ្រងរាល់ពិធីការផ្លូវការ ក្នុងឱកាសរៀបចំទទួល និងជូនព្រះរាជដំណើរព្រះមហាក្សត្រ ទទួលនិងជូនដំណើរគណៈប្រតិភូជាន់ខ្ពស់ជាតិ-អន្តរជាតិជាផ្លូវការ ។
- ទទួលបន្ទុកចាត់តាំង និងរៀបចំកម្មវិធីបើកសន្និសីទ និងពិធីក្នុងការទទួល-ជូនដំណើរទស្សនកិច្ចផ្លូវការ ក្នុងប្រទេសកម្ពុជារបស់ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល ប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា ក្នុងឋានៈជាភ្ញៀវរបស់រដ្ឋ ។
- ទទួលបន្ទុកចាត់តាំងរៀបចំសន្និបាត សន្និសីទ ឬសិក្ខាសាលាកម្រិតជាតិ និងអន្តរជាតិ ការតាំងពិព័រណ៍ជាតិ និងអន្តរជាតិ និងប្រជុំផ្សេងៗទៀត ដូចជា សន្និសីទអន្តរជាតិថ្នាក់រដ្ឋមន្ត្រី និងសន្និសីទកំពូលថ្នាក់ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល តាមការសម្រេចរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។
- រៀបចំសេចក្តីព្រាងសារាចរ សេចក្តីសម្រេច និងផែនការណែនាំ នៃពិធីបុណ្យនីមួយៗជូនទីស្តីការគណៈរដ្ឋមន្ត្រី ។
- លើកគំរោង និងកោះប្រជុំ កំណត់បែងចែកភារកិច្ចជូនក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងខេត្ត-ក្រុងពាក់ព័ន្ធ តាមជាន់ថ្នាក់ដោយស្ថានការណ៍ ការងារចុះសួរសុខទុក្ខប្រជាជនក្រីក្រ អ្នករបួស ពិការ តាមមន្ទីរពេទ្យ កុមារកំព្រា ចាស់ព្រឹទ្ធាចារ្យគ្មានទីពឹង ដោយមានការឯកភាពពីទីស្តីការគណៈរដ្ឋមន្ត្រី និងតាមស្មារតីសារាចរ និងការណែនាំរបស់រាជរដ្ឋាភិបាល ។
- រៀបចំចងក្រង និងកំណត់បែបបទជាពិធីការជាតិមួយ សម្រាប់ទិវានីមួយៗស្របតាមប្រពៃណី ទំនៀមទម្លាប់ជាតិ និងអន្តរជាតិ ។
- ចងក្រង បោះពុម្ពប្រតិទិនឈប់សម្រាកប្រចាំឆ្នាំ នៃមន្ត្រីរាជការ និយោជិត កម្មករ និងមហាសង្ក្រាន្ត ប្រតិទិនចន្ទគតិ-សុរិយគតិប្រចាំឆ្នាំ សម្រាប់ឯកភាពប្រើប្រាស់ជាសកលក្នុងទូទាំងប្រទេស ស្នើសុំសេចក្តីសម្រេចពីទីស្តីការគណៈរដ្ឋមន្ត្រី ។

- លើកគំរោងថវិកាចំណាយបូកសរុប សំរាប់រៀបចំបុណ្យប្រពៃណីជាតិ បុណ្យជាតិ បុណ្យអន្តរជាតិ និងបុណ្យប្រចាំឆ្នាំ និងទទួល-ជូនដំណើរគណៈប្រតិភូជាន់ខ្ពស់ជាតិ-អន្តរជាតិ ស្នើសុំយោបល់សំរេចពីទីស្តីការគណៈរដ្ឋមន្ត្រី ។
- ប្រមូលបូកសរុបលទ្ធផលនៃការអនុវត្ត ការងារក្នុងការរៀបចំពិធីបុណ្យនីមួយៗ ជូនទីស្តីការគណៈរដ្ឋមន្ត្រី ។
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលទីស្តីការគណៈរដ្ឋមន្ត្រីប្រគល់ជូន ។

មាត្រា ៤ .- អគ្គលេខាធិការដ្ឋាន នៃគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ត្រូវធ្វើការកោះប្រជុំការងារតាមតំរូវការជាក់ស្តែង និងតាមការណែនាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ៥ .- អគ្គលេខាធិការដ្ឋាន នៃគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ មានសិទ្ធិប្រើប្រាស់ត្រារបស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ដែលមានស្រាប់ ដើម្បីបំពេញការងាររបស់ខ្លួន ។

មាត្រា ៦ .- អគ្គលេខាធិការដ្ឋាន មានសិទ្ធិលើកសំណើជូនទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងសំរេចលើសេចក្តីប្រកាសតែងតាំង ផ្ទេរភារកិច្ច ឬដកចេញពីតំណែងនូវមន្ត្រី បុគ្គលិក ថ្នាក់ក្រោមប្រធាននាយកដ្ឋានរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ។

## ជំពូកទី ៣

## រចនាសម្ព័ន្ធ

មាត្រា ៧ .- អគ្គលេខាធិការដ្ឋាននៃគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ មានរចនាសម្ព័ន្ធ ដូចតទៅ ៖

១- ក្រុមរដ្ឋបាល បុគ្គលិក និងស្រាវជ្រាវបោះពុម្ពផ្សាយ

២- ក្រុមពិធីការ និងបដិសណ្ឋារកិច្ច

៣- ក្រុមផែនការគណនេយ្យ

មាត្រា ៨ .- ការបែងចែកភារកិច្ចលំអិតរបស់បុគ្គលិក និងមន្ត្រីរាជការ ដែលបំរើការងារនៅក្នុងអគ្គលេខាធិការដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។ ប្រធានក្រុមនីមួយៗមានឋានៈស្មើប្រធាននាយកដ្ឋាន ។

មាត្រា ៩ .- ក្រុមរដ្ឋបាលបុគ្គលិក និងស្រាវជ្រាវបោះពុម្ពផ្សាយ ដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានតាមការចាំបាច់ ។

<u>ក្រុមរដ្ឋបាលបុគ្គលិក និងបោះពុម្ពផ្សាយ មានមុខងារ និងភារកិច្ច ដូចតទៅ</u> ៖

- ទទួលខុសត្រូវផ្នែករដ្ឋបាល ។
- ទទួលខុសត្រូវការងាររៀបចំកសាងសំណុំលិខិតឯកសារចេញ-ចូលផ្សេងៗ ។
- បើកតំរោងផែនការបុណ្យនីមួយៗ កំណត់បែងចែកភារកិច្ចសមាជិក កោះអញ្ជើញប្រជុំ ធ្វើកំណត់ហេតុប្រជុំ អញ្ជើញបណ្តាញសារព័ត៌មាន គ្រប់ពិធីបុណ្យ ។
- ព្រាងអត្ថបទបទដ្ឋាននានា សារាចរ ផែនការណែនាំ សេចក្តីសំរេច សេចក្តីថ្លែងអំណរគុណ និងសេចក្តីអំពាវនាវផ្សេងៗក្នុងពិធីបុណ្យ ។
- គ្រប់គ្រងមន្ត្រីរាជការ វត្តមាន អវត្តមាន ធ្វើតារាងជូនរង្វាន់សរសើរ និងដាក់ពិន័យ ។
- រៀបចំ តុបតែងលំអ ទង់បដា ពាក្យស្លោក ក្នុងពិធីបុណ្យផ្សេងៗ ។
- រក្សាការងារសន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យ ។
- ធ្វើវេទិកា តុបតែងលំអឡូង បដា ពាក្យស្លោក ។ល។
- ធ្វើសារលិខិតថ្វាយព្រះពរព្រះមហាក្សត្រ ជូនពរថ្នាក់ដឹកនាំ អត្ថបទព្រាងគាថា-វិយោគកថា ។
- ស្រាវជ្រាវប្រវត្តិប្រពៃណី ទំនៀមទំលាប់បុណ្យជាតិ បុណ្យទ្វាទសមាស ។
- ស្រាវជ្រាវធ្វើមហាសង្ក្រាន្ត-ប្រតិទិន ចន្ទគតិ-សុរិយគតិប្រចាំឆ្នាំ ។
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ។

មាត្រា ១០ .- ក្រុមពិធីការ និងបដិសណ្ឋារកិច្ច ដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានតាមការចាំបាច់ ។

<u>ក្រុមពិធីការ និងបដិសណ្ឋារកិច្ច មានមុខងារ និងភារកិច្ច ដូចតទៅ</u> ៖

- ទទួលខុសត្រូវផ្នែកពិធីការរួមពិធីជាតិធំៗ ដូចជាទិវាបុណ្យជាតិ និងពិធីទទួល-ជូនដំណើរប្រតិភូជាន់ខ្ពស់ជាតិ-អន្តរជាតិ ដោយសហការជាមួយនាយកដ្ឋានពិធីការ នៃទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងករណីចាំបាច់ ។
- សិក្សា ចងក្រង កំណត់បែបបទពិធីការ តាមទិវានីមួយៗឲ្យក្លាយទៅជាពិធីការជាតិ ។
- ធ្វើលិខិតអញ្ជើញថ្នាក់ដឹកនាំជាតិ និងភ្ញៀវអន្តរជាតិចូលរួមគ្រប់ពិធី តាមការកំណត់ ។
- រៀបចំពិធីការ ធ្វើប្លង់អាសនៈតាមឋានានុក្រម បិទឈ្មោះតាមការជាក់ស្តែង ។
- រៀបចំពិធីការក្នុងការប្រជុំ បំរើភ្ញៀវ អញ្ជើញ និងទទួលភ្ញៀវ ។
- ធ្វើលិខិតជូនពរ ចំពោះឥស្សរជនជាតិ-អន្តរជាតិ ក្នុងករណីចាំបាច់ ។
- កាន់កម្មវិធី ស្រែកជ័យឃោសន៍ ។

**មាត្រា ១១ .-** ក្រុមផែនការ គណនេយ្យ ដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានតាមការចាំបាច់ ។

<u>ក្រុមផែនការគណនេយ្យ មានមុខងារ និងភារកិច្ច ដូចតទៅ</u> ៖

- ទទួលខុសត្រូវផ្នែកផែនការគណនេយ្យ ។
- រៀបចំគំរោងថវិកា គំរោងសំភារៈបរិក្ខារ មធ្យោបាយការងារផ្សេងៗ ដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រី ។
- គ្រប់គ្រងអចលនវត្ថុ ចលនវត្ថុ និងរាល់ការចំណាយផ្សេងៗរបស់អគ្គលេខាធិការដ្ឋាន ។
- លើកគំរោងការចំណាយក្នុងពិធីបុណ្យនីមួយៗ និងទទួលគណៈប្រតិភូជាន់ខ្ពស់ជាតិ-អន្តរជាតិ ។
- គ្រប់គ្រងដោះស្រាយប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនមន្ត្រីរាជការ បុគ្គលិក ។
- ធ្វើរបាយការណ៍បូកសរុបថវិកា និងចំណាយថវិកាក្នុងពិធីបុណ្យ និងទទួលគណៈប្រតិភូនីមួយៗ ជូនទីស្តីការគណៈរដ្ឋមន្ត្រី ។
- លើកគំរោងចំណាយម្ហូបអាហារ ផ្លែឈើ សាបូ ទឹក ។ល។
- ទទួលរក្សាកម្រងឯកសារ អនាម័យ ភ្លើង ទឹក អគាររបស់អង្គភាព និងទីស្ថានក្រសួង ។
- ធ្វើទំនាក់ទំនងការងារថវិកា ជាមួយទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងធនាគារ ។
- ទទួលខុសត្រូវចំពោះមុខអគ្គលេខាធិការ និងភ្នាក់ងារហិរញ្ញវត្ថុក្នុងការប្រើប្រាស់ថវិកា ។
- ផ្គត់ផ្គង់ភោគផ្គៈរាល់គ្រប់ពិធីប្រជុំ ពិធីបុណ្យផ្សេងៗ និងក្រោយគ្រប់ពិធីបុណ្យ ។

**មាត្រា ១២ .-** អគ្គលេខាធិការដ្ឋានប្រើប្រាស់ បុគ្គលិក នៃមុខងារសាធារណៈ ឬអាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ។ លក្ខខណ្ឌនៃការងាររបស់ភ្នាក់ងារជាប់កិច្ចសន្យា និងប្រាក់បំណាច់ពិសេសសំរាប់បើកជូនភ្នាក់ងារ នៃមុខងារសាធារណៈ ត្រូវកំណត់ដោយប្រកាសរបស់ទីស្តីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់អគ្គលេខាធិការ ។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា ១៣ .-** ការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ចាប់ពីក្រោមថ្នាក់ប្រធាននាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាស

របស់ទីស្ដីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់អគ្គលេខាធិការ នៃគណៈកម្មការអចិន្ត្រៃយ៍រៀបចំពិធីបុណ្យជាតិ-អន្តរជាតិ ។

**មាត្រា ១៤ .-** បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៥ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន និងសមាជិកទាំងអស់នៃគណៈកម្មការអចិន្ត្រៃយ៍រៀបចំពិធីបុណ្យជាតិ អន្តរជាតិ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

***

# រចនាសម្ព័ន្ធ នៃអគ្គលេខាធិការដ្ឋាន
# គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ




★★★

## អនុក្រឹត្យ ១០២ អនក្រ.បក
### ស្តីពីការផ្ទេរភ័ណ្ឌខាន

***

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រម ០៧/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រម នស/រកម/០១៩៩/០១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩
- បានឃើញ អនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៩
- បានឃើញ អនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការផ្ទេរចំណូល និងផ្ទេរឥណទានថវិកា សំរាប់ក្រសួងស្ថាប័នថ្មី
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១ .-** ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកា ចំនួន ៣៥ លានរៀល (សាមសិបប្រាំលានរៀល) ពីជំពូក ៩១ (ចំណាយឥតគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការផ្គត់ផ្គង់) របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩ ។

**មាត្រា ២ .-** ឥណទានថវិកាក្នុងមាត្រា ១ ខាងលើត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ សំរាប់ប្រារព្ធទិវាមនុស្សចាស់អន្តរជាតិ និងជួយជនចាស់ជរា ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩

**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា និង ត្រា**
**ហ៊ុន សែន**

**បានយកសេចក្តីជំរាបជូន**
**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**
**រដ្ឋមន្ត្រីស្តីទី**
**ហត្ថលេខា និង ត្រា**
**ស៊ុក ចំរ៉ុន**

# អនុក្រឹត្យ ១០៣ អនក្រ.បក
## ស្តីពីការផ្ទេរឥណទាន

***

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រម នស/រកម/០១៩៩/០១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩
- បានឃើញ អនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការបែងចែកឥណទានថវិកាតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៩
- បានឃើញ អនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការផ្ទេរចំណូល និងផ្ទេរឥណទានថវិកា សំរាប់ក្រសួងស្ថាប័នថ្មី
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

មាត្រា ១.- ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកា ចំនួន ៥០០. លានរៀល (ប្រាំរយលានរៀល) ពីជំពូក ៣១ (អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច និងវប្បធម៌) មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលថែទាំ) របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩ ។

មាត្រា ២.- ឥណទានថវិកាក្នុងមាត្រា ១ ខាងលើត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ សំរាប់ចំណាយដំណើរការរដ្ឋបាលដែលខ្វះខាតក្នុងឆ្នាំ ១៩៩៩ ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាំងពីថ្ងៃចុះហត្ថលេខា តទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ហត្ថលេខា និង ត្រា

គាត ឈន់

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

***

## អនុក្រឹត្យលេខ ១០៨ អនក្រ.បក

## ស្តីពីការផ្ទេរឥណទាន

***

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រម នរ/រកម/០១៩៩/០១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩

- បានឃើញ អនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៩ ស្ដីពីការបែងចែកឥណទានចំណាយតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩
- បានឃើញ អនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៩ ស្ដីពីការផ្ទេរចំណូល និងផ្ទេរឥណទានថវិកា សំរាប់ក្រសួងស្ថាប័នថ្មី
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

មាត្រា ១ .- ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកា ចំនួន ៦៩ លានរៀល (ហុកសិបប្រាំបួនលានរៀល) ពីជំពូក ៩១ (ចំណាយមិនបានគ្រោងទុក) នៃថវិកាមិនទាន់បែងចែក មកជំពូក ៣២ (អង្គភាពសហប្រតិបត្តិការអន្តរជាតិ វិភាគទានឲ្យអង្គការអន្តរជាតិនានា) របស់ថវិកា សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩ ។

មាត្រា ២ .- ឥណទានថវិកាក្នុងមាត្រា ១ ខាងលើត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ សំរាប់បង់វិភាគទានសមាជិកភាពទៅកាន់អង្គការអន្តរជាតិ ។

មាត្រា ៣ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្ដេចក្រុមព្រះ ព្រះប្រធានរដ្ឋសភា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
**ហ៊ុន សែន**

បានជំរាបជូន
សម្ដេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា
ហត្ថលេខា និង ត្រា
**គាត ឈន់**
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

***

## អនុក្រឹត្យលេខ ៥៣៧ អនក្រ.តត
## ស្ដីពីការតែងតាំងក្រុមប្រឹក្សាភិបាលនៃមន្ទីរពេទ្យកាល់ម៉ែត

***

**រាជរដ្ឋាភិបាល**

- **បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា**
- **បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា**

- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្ដីពីលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៦/៩៥ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ស្ដីពីការបង្កើតមន្ទីរពេទ្យកាល់ម៉ែត ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

មាត្រា ១ .- តែងតាំងលោក ម៉ៅ ធឿន បច្ចុប្បន្នអនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិកក្រុមប្រឹក្សាភិបាល នៃមន្ទីរពេទ្យកាល់ម៉ែត ជំនួសលោក សាយ មឹនឃេង ដែលបានចូលនិវត្តន៍ ។

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

***

## អនុក្រឹត្យលេខ ៥៣៨ អនក្រ.តត
## ស្ដីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញ ព្រះរាជក្រមលេខ ០៦/នស/៩៥ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកត/០១៩៦/២៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- យោងតាមសំណូមពររបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

**សំរេច**

មាត្រា ១ .- ត្រូវបានតែងតាំងលោកស្រី ខេង **សុខនី** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានសិក្សាបណ្តុះបណ្តាលផ្លូវអាកាស ជាប្រធាននាយកដ្ឋានសិក្សាបណ្តុះបណ្តាលផ្លូវអាកាស នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ។

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ឱ្យបានសំរេចចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៥៣៩ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

**រាជរដ្ឋាភិបាល**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណូមពររបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១ .-** តែងតាំងលោក **ប្រាក់ ស៊ីហារ៉ា** ជាអគ្គនាយករងទី១ នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ។

**មាត្រា ២ .-** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ តាំងពីថ្ងៃចុះ ហត្ថលេខាតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

## ២-សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩

### សេចក្តីសំរេចលេខ ៧៥ សសរ.

### ស្តីពីការបន្ថែមសមាសភាពនៃគណៈកម្មការជាតិយូណេស្កូ កម្ពុជា

***

**រាជរដ្ឋាភិបាល**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ សេចក្តីសំរេចលេខ ៣៩ សសរ. ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការបង្កើតគណៈកម្មការយូណេស្កូ កម្ពុជា
- យោងតាមសំណូមពររបស់គណៈកម្មការជាតិយូណេស្កូ-កម្ពុជា

សម្រេច

ប្រការ ១ : តែងតាំងលោកជំទាវ ស៊ិន សាឃឿន អនុរដ្ឋលេខាធិការ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាអនុប្រធាននៃគណៈកម្មការជាតិយូណេស្កូ កម្ពុជា ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ប្រធានគណៈកម្មការជាតិយូណេស្កូកម្ពុជា ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាំងពីថ្ងៃចុះហត្ថលេខា តទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩

## សេចក្តីសម្រេចលេខ ៧៦ សសរ.

### ស្តីពីការផ្លាស់ប្តូរសមាសភាពនៃគណៈកម្មការជាតិយូណេស្កូ កម្ពុជា

***

### រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ សេចក្តីសម្រេចលេខ ៣៩ សសរ. ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការបង្កើតគណៈកម្មការយូណេស្កូ កម្ពុជា
- យោងតាមសំណើរបស់គណៈកម្មការជាតិយូណេស្កូ កម្ពុជា

សម្រេច

ប្រការ ១ : តែងតាំងលោក យស់ អ៊ិន ប្រធាននាយកដ្ឋានរដ្ឋបាល ក្រសួងអប់រំ យុវជន និងកីឡា ជាអគ្គលេខាធិការរង នៃគណៈកម្មការជាតិយូណេស្កូ កម្ពុជា តំណាងក្រសួងអប់រំ យុវជន និងកីឡា ជំនួសលោក យ៉ង់ យ៉ាណូ វិញ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងក្រសួងអប់រំ យុវជន និងកីឡា ប្រធានគណៈកម្មការជាតិយូណេស្កូកម្ពុជា ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាំងពីថ្ងៃចុះហត្ថលេខា តទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

# III- ភាគខាងបណ្តាក្រសួង

## ១-ទីស្តីការគណៈរដ្ឋមន្ត្រី

### ១.ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩

**ប្រកាសលេខ ១៥២ ប្រក.**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

***

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងលិខិតលេខ ៣៩ សគស.គគ ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- យោងតាមការចាំបាច់របស់ទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

ប្រការ ១ : តែងតាំងលោក សេង ឡេង ជាអនុប្រធាននាយកដ្ឋានពិធីការ នៃទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ ២ : លោកប្រធាននាយកដ្ឋានរដ្ឋបាល-បុគ្គលិក នាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញវត្ថុ នាយកដ្ឋានពិធីការ ព្រមទាំងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
សុខ អាន

***

## ២.សេចក្តីជូនដំណឹង

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩

### សេចក្តីជូនដំណឹងលេខ ១៦៥៨ សជណ.

### ស្តីពីលក្ខណៈត្រឹមត្រូវនៃព្រះរាជក្រឹត្យ

### លេខ នស/រកត/១១៩៩/១៩១

***

ដោយមានបញ្ហាបច្ចេកទេស អគ្គលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាល សូមទូលថ្វាយ និងជំរាបជូនសម្តេច ព្រះអង្គម្ចាស់ លោកជំទាវ រដ្ឋមន្ត្រីរដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន នៃរាជរដ្ឋាភិបាលកម្ពុជាទាំងអស់ សូមទ្រង់ព្រះមេត្តា និងសូមមេត្តា ទទួលយកជាបានការនូវព្រះរាជក្រឹត្យលេខ នស/រកត/១១៩៩/១៩១ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ស្តីពីការតែងតាំងឯកឧត្តម **ជា សុផារ៉ា** ដែលមានចែង ក្នុងមាត្រា ១ ដូចតទៅ ៖

“មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម **ជា សុផារ៉ា** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអភិបាលរងទី ១ រាជធានីភ្នំពេញ ជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ” ។

**ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៩/១៩១ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលមាន “មាត្រា ១ ត្រូវបានតែងតាំងឯកឧត្តម ជា សុផារ៉ា ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអភិបាលរងទី ១ រាជធានីភ្នំពេញ ជាអភិបាលរាជធានីភ្នំពេញ ” ត្រូវទុកជាមោឃៈ ។**

អគ្គលេខាធិការដ្ឋាន នៃរាជរដ្ឋាភិបាល សូមសំដែងនូវសេចក្តីសោកស្តាយចំពោះកំហុសបច្ចេកទេសដោយអចេតនានេះ ។

សូមសម្តេច ព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ទ្រង់ព្រះមេត្តា មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីទូលបង្គំខ្ញុំ ផងចុះ ។

អគ្គលេខាធិការរាជរដ្ឋាភិបាល

អគ្គលេខា ពិន ត្រា

ណាឡី តាន់

★★★

## ២-ធនាគារជាតិនៃកម្ពុជា

### ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩

**ប្រកាសលេខ ធ២ ៩៩.១២១ ប្រក.**

**ស្តីពីប្រព័ន្ធគណនេយ្យរបស់ធនាគារជាតិ នៃកម្ពុជា**

***

**ទេសាភិបាលធនាគារជាតិ នៃកម្ពុជា**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃធនាគារជាតិ នៃកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៨/៩៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលធនាគារជាតិ នៃកម្ពុជា
- យោងតាមការអនុម័តរបស់អង្គប្រជុំក្រុមប្រឹក្សាភិបាលធនាគារជាតិ នៃកម្ពុជា ថ្ងៃទី ១១ វិច្ឆិកា ១៩៩៩

**សំរេច**

**ប្រការ ១ :** ដាក់ឱ្យប្រើប្រាស់នូវប្លង់គណនីរបស់ធនាគារជាតិ នៃកម្ពុជា ។

**ប្រការ ២ :** បទបញ្ញត្តិគណនេយ្យ ស្តីពីការចុះបញ្ជីកាលកំណត់ ចំពោះប្រភេទប្រតិបត្តិការនីមួយៗ ដោយផ្អែកលើប្លង់គណនីនេះ ត្រូវកំណត់ដោយឡែក ។

**ប្រការ ៣ :** រាល់ប្រកាសបទបញ្ញា និងសេចក្តីណែនាំ ស្តីពីប្រព័ន្ធគណនេយ្យ និងរបាយការគណនេយ្យ ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤ :** រដ្ឋលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គលេខា អគ្គាធិការដ្ឋាន និងគ្រប់នាយកដ្ឋាន-អង្គភាព នៅក្រោមឱវាទធនាគារជាតិ នៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់ប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៥ :** ប្រកាសនេះ មានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ទេសាភិបាល

ហត្ថលេខា និង ត្រា

ជា ចាន់តូ

★★★